# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និង អក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ លោក ភិយ-ប៊ុក
ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកសាសនាៈ ព្រះទេពសត្ថា ស៊ូរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
| --- | --- | --- |
| លោក ភិយ-ប៊ុក ក្រមការ | ឧភិទមហាភ្នំ (តមក) . . . . . . . . . . | ៣២១ |
| — — | ប្រវត្តិសាស្ត្រនៃសុវណ្ណខ្មែរសម័យបុរាណ (តមក) | ៣២៦ |
| ក្រុមជំនុំវប្បធម៌ | ស័ព្ទបារាំងប្រែជាខ្មែរ ញ៉ូក-ថែម ស្រង់ (តមក) | ៣២៩ |
| លោកសាំង-សាភិត លេខានុការ | រឿងព្រែងភូមា (តមក) . . . . . . . . . . | ៣៣៣ |
| អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន | រឿងសាមកុក (តមក) . . . . . . . . . . . . . . . . . | ៣៤០ |
| — ទេពពិទូរ ឈឹម-ក្រសេម | ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) . . . | ៣៤៨ |
| ឧៀមទម្លាប់ស្រុកខ្មែរ | សាវតារវត្តវិហារទន្ទឹម អ្នកឧកញ៉ាកែវ-ហង់ តែង | ៣៥៣ |

| សាសនា | | |
| --- | --- | --- |
| ប-ប៊ុក ក្រមការ | គន្ធិអាស៊ីទ្វីប (តមក) . . . . . . . . . . . | ៣៦១ |
| ឮ-តាំត្រី | ពុទ្ធសាសនានិងពាហិរសាសនា (តមក) ... | ៣៦៦ |
| ស្លាស៊ូរ-ហាយ | សប្បុរិសធម្មកថា . . . . . . . . . . . | ៣៧៥ |
| វេទី យូរ-អ៊ុន | វសលសូត្រ ប្រែជាពាក្យកាព្យ . . . . . . | ៣៨១ |

| កណាតទីនប្រវត្តិការណ៍ | | |
| --- | --- | --- |
| ព្រះឧបហាៈ កែ-អៀន | ពិធីបុណ្យធំឧឡារិក នៅវត្តដំណាក់ (សៀមរាប) | ៣៩៤ |
| ក្រសួងធម្មការ | ចៅអធិការដែលទើបតាំងថ្មី (តមក) ...... | ៣៩៧ |

ឆ្នាំទី ២២ – លេខ ៥ ខែឧសភា ឆ្នាំ ១៩៥០ — តំឡៃជាវ ១ ឆ្នាំ ១៤៥ រៀល ។

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déba Sattha So-Hay membre de la Commission du Tripitaka

## TABLE DES MATIÈRES

**Partie littéraire:**

| | | page |
|---|---|---|
| M. Ray-Buc Kramakar (I.B.) | Paroles de GANDHI ( suite )....... | 321 |
| —id — | Histoire: Ancienne civilisation khmère par M. George GOEDES (suite) ... | 326 |
| Commission Culturelle | Recueil des mots traduits fait par M· NHOK-THEM ( suite )......... | 329 |
| M. Sang-Savath Secrétaire au Ministère des Finances | Contes birmans ( suite )............ | 333 |
| Neak Oknha Vipularaja-sena Nou-Kan | Histoire de SAMKOK ( suite )........ | 340 |
| Neak Oknha Debabidura Chhim-Krasem | Histoire du Royaume du Cambodge (suite)......................... | 348 |
| Commission des Mœurs et Coutumes | Notice historique de la pagode de Vat Vihara-Tontim (Suong-Kg. Cham) par Neak Oknha Keo-Hang ........ | 353 |

**Partie religieuse:**

| | | |
|---|---|---|
| M. Ray-Buc Kramakar | Lumière de l'Asie (suite) ......... | 361 |
| M. Menh-Nakry | Le bouddhisme et les autres religions (suite) ......................... | 366 |
| Brah Debasattha So-Hay | Sappurisaddhammakatha .......... | 374 |
| Khun Suvatthi vedi You-Oun | Vasalasutta (Poème) ............ | 381 |

**Notes et Chroniques:**

| | | |
|---|---|---|
| Brah Maha Ker-Oeun | Compte rendu des cérémonies religieuses célébrées à Vat Damnak ( Siemreap) .................... | 394 |
| Ministère des Cultes | Nomination des nouveaux Chau-Adhikar (suite) ............... | 398 |

22e Année: No 5 mois d' Mai 1950 — Prix d'abonnement: 145$00 par an.

ឱវាទមហាត្មគន្ធី

# លោក ភ័យ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

ដកស្រង់ពីសារពត៌មាន ហ្សឺនអាំង (Jeune Inde)

(តទៅ)

២០ — វប្បធម៌មានការទាក់ទងនឹងសេចក្ដីទុក្ខដែលបុគ្គលទទួល, បើសេចក្ដីទុក្ខនោះមានសភាពបរិសុទ្ធ វប្បធម៌ក៏មាំមួនអស្ចារ្យ ។

ច្បាប់នៃទុក្ខសច្ច
(១៦-៦-១៩២០)

២១ — អាហារណាដែលយើងបរិភោគក្នុងកាលនៅជាទារក, ដល់យើងចំរើនវ័យវប្បនាការធំឡើង អាហារនោះត្រូវផ្លាស់ចេញ ត្រូវរកអាហារថ្មីបរិភោគវិញ ។

បដិវត្តន៍ ពួកក្រុមប្រឹក្សា
(១៤-៧-១៩២០)

២២ — ការរំលំរដ្ឋាភិបាល ដែលគ្មានសមត្ថភាពត្រួតត្រាប្រទេសជាកិច្ចស្រួលងាយ ជាងការមើលដំងឹងតរបស់ប្រជាជនឲ្យជាសះស្បើយ ។

ថ្ងៃទីមួយខែឧសភា
(២៨-៧- ៩២០)

២៣ — យើងត្រូវសិក្សារៀនសូត្រ ហើយត្រូវធ្វើតយកផលប្រយោជន៍អំពីកិច្ចការណាដែលយើងបានប្រព្រឹត្តខុស ឬ កាន់ច្រឡំឲ្យបានត្រឹមត្រូវឡើងវិញ ។

. . . គ្មានមេទ័ពណាមួយឈប់ធ្វើចម្បាំង ដោយហេតុគ្រាន់តែបានទទួលបរាជ័យ ឬភាន់ច្រឡំក្នុងរណសាស្ត្រទេ ។

. . . ពួកពលរដ្ឋត្រូវទទួលការខុសត្រូវចំពោះករណីយកិច្ចនៃរដ្ឋាភិបាល ។

ថ្ងៃទីមួយខែភ្ជិត
(២៨.៣-១៩៦២ )

២៤ — ក្នុងករណីយកិច្ចរបស់យើង បើមានយោបល់ខ្វែងគ្នា យើងត្រូវយកសំឡេងតូចស្ងាត់ដែលនៅក្នុងសន្តានយើង ជាអាជ្ញាកណ្តាល ។

. . . នៅក្នុងវិជ្ជាឋានទីមួយៗ មានមនុស្សបីពួក គឺ មួយពួកមានសេចក្តីពេញចិត្តខាងធ្វើតាមនយោបាយដែលគេបានកំណត់ទុកមុន; មួយពួកយល់ឃើញថានយោបាយនេះគួរធ្វើ តែមិនព្រមធ្វើ; មួយពួកទៀតមិនយល់នូវនយោបាយនេះសោះឡើយ ។

សភាកុងគ្រេសនិអសាធគ្គិភាព
(៦-៩-១៩៦២ )

២៥ — ខ្ញុំចូលចិត្តឲ្យប្រទេសឥណ្ឌៀប្រើអាវុធយុទ្ធភណ្ឌ ដើម្បីការពារនូវកិត្តិយសរបស់ជាតិ មិនមែនខ្ញុំចង់ឲ្យប្រទេសនេះមានសភាពអន់ខ្សោយដែលជាសាក្សីចំពោះសេចក្តីអប្បកិត្តិយសនៃជាតិទេ ។

· · · តែខ្ញុំយល់ថា អហឹង្សាវិតក្ក: (non-violence) ជាសភាពវិសេសជាងកំហឹង ( ទារុណកម្ម ), ការអត់ឱនជាគុណប្រសើរជាងធ្វើទណ្ឌកម្ម, សេចក្តីអត់ឱន ជាគ្រឿងអលង្ការរបស់ទាហាន, តែការមិនធ្វើទណ្ឌកម្ម

នេះ នឹងទុកថាជាសេចក្ដីអត់ឱនទោសបាន លុះត្រាតែកិច្ចដែលប្រព្រឹត្តនោះ ជាហេតុគួរឲ្យធ្វើទណ្ឌកម្ម ។ ការមិនព្រមផ្ដន្ទាទោស ទុកជាអសារឥតការ បើកិច្ចនោះធ្វើដោយសេចក្ដីទុព្វលភាពរបស់ខ្លួន, គេមិនអាចពោលថាករុណាអត់ទោសឲ្យឆ្មាក្នុងវេលាដែលឆ្មាកំពុងខាំកកេរកណ្ដុរទេ ។

...ពលភាពមិនមែនកើតមកពីកំឡាំងកាយ គឺកើតមកពីឆន្ទៈដ៏ខ្លាំងក្លារបស់ចិត្ត ។

...លទ្ធិអហឹសាវិតក្កៈនេះ មិនមែនមានតែក្នុងពួកឥសី ឬព្រះខីណា-ស្រពទេ ក្នុងពួកហីនជាតិក៏មានដែរ, អហឹសាវិតក្កៈជាច្បាប់មនុស្សជាតិ, ទារុណកម្មជាច្បាប់តិរច្ឆាន ។ វិញ្ញាណដេកសំងំនៅក្នុងសត្វតិរច្ឆាន តែសត្វតិរច្ឆានមិនអាចដឹងអ្វីក្រៅពីកាយពលភាព, សភាពថ្លៃថ្នូររបស់មនុស្សនៅត្រង់ការប្រតិបត្តិតាមច្បាប់ដ៏ឧត្ដម គឺកំឡាំងមនោវិញ្ញាណដ៏បរិសុទ្ធ ។

...ខ្ញុំមានប្រាថ្នាយ៉ាងមុតមាំថា ធ្វើម្ដេចហ្ន៎ ឲ្យប្រទេសឥណ្ឌាដឹងខ្លួនដោយខ្លួនឯងថាខ្លួនមានដួងវិញ្ញាណមិនចេះស្លាប់ ហើយអាចនឹងតស៊ូនូវសេចក្ដីខ្សត់ខ្សោយខាងសម្ភារៈរបស់ជាតិ ទាំងអាចទប់ទល់ក្នុងការបលា-បលខាងសម្ភារៈក្នុងសកលលោក ។

... ចិត្តខ្ញុំជាប់ស្អិតនឹងប្រទេសឥណ្ឌា ព្រោះខ្ញុំនៅជាប់ជំពាក់ក្នុងប្រទេសនេះច្រើនស្ថាន ។

... ខ្ញុំស្អប់ការស្ងាត់កំបាំងដូចជាទោសឧក្រិដ្ឋ ។

ព. ទិ ព្រះវ័នពេជ្រ
(១១-៨-១៩២០)

២៦– មិនចាំបាច់ពិចារណាឲ្យយូរទេគង់យល់បានថា រដ្ឋាភិបាលដែលមានសិទ្ធិតាំងនៅមាំមួនបាន មកពីអំណាចសាលាតុលាការ ហើយរដ្ឋាភិបាលនេះដែលតុបតែងមន្ត្រីគ្រប់តំណែងបាន មកពីសាលារៀន, សាលាទាំងពីរនេះជាវិជ្ជាស្ថានមានប្រយោជន៍ បើរដ្ឋាភិបាលទទួលការខុសត្រូវរក្សាវិន័យសុចរិត, ជាវិជ្ជាស្ថានដូចជាអង្កប់របស់ប្រជាជន បើរដ្ឋាភិបាលប្រព្រឹត្តទុច្ចរិត ។

កម្មវិធីនៃអសាមគ្គីភាព
(១៩-៨-១៩២០)

២៧– ខ្ញុំពេញចិត្តជាអនេកប្បការក្នុងការកាន់អំបែងនៃសុម្ពយាចក ជាជាងការទទួលនូវវត្ថុដ៏ប្រសើរអំពីពួកអ្នកមានដៃប្រឡាក់លោហិតក្នុងការចលាចលនៅសល្ល័យ៉ាន់វ៉ាឡាបាគ្ហ (Jallianwala agh), ខ្ញុំចូលចិត្តកាន់ដីកាឃុំខ្លួនជាជាងការស្តាប់ពាក្យផ្អែមដូចទឹកឃ្មុំ នៃពួកដែលធ្វើឲ្យមនោសញ្ចេតនាហាររបស់ពួកបងប្អូនកាន់សាស្នាមហាម័តទាំង ៧០ លាននាក់ឲ្យអាក់អន់ស្រពន់ចិត្ត ។

ពុទ្ធៈហេតុសាសនានៃអសាមគ្គីភាព
(២៥-៨-១៩២០)

២៨– គួរតែបោសសំអាតមន្ទិលចេញពីសាសនា, តែជាការគួរណាស់បង្ហាញនូវសេចក្ដីបំណងក្នុងសីលធម៌ដែលគ្មានខ្លឹមសារ របស់អ្នកពេញចិត្តខាងការស្វែងរកប្រយោជន៍សម្ភារៈជាងប្រយោជន៍សីលធម៌ ជាហេតុឲ្យសីលធម៌ទន់អន់គ្មានខ្លឹមសារ, ការដឹកនាំពួកអធិមុត្តកៈ (អ្នកចុះចិត្តស៊ប់) (Fanatique) ដែលមានសភាពល្ងង់ខ្លៅឲ្យលះបង់ការប្រព្រឹត្តខុសស្រួលជាងការដឹកនាំពួកចោរបាសដែលមានចិត្តជាប់មាំតែនឹងការលួចប្លន់ឲ្យលះបង់នូវអំពើទុច្ចរិត ។

ចរិយាដ៏ស្និទ្ធស្នាលនៃលទ្ធិអសាមគ្គីភាព
(៨-៩-១៩២០)

២៩ – ប្រជាជាតិមិនអាចនឹងឡើងទៅកាន់វឌ្ឍនធម៌បានទេ បើប្រជាជាតិនោះពឹងផ្អែកតែលើខ្ញុំម្នាក់ឯង; សេចក្ដីចំរើនដែលនឹងកើតមានឡើង លុះត្រាតែប្រជារាស្ត្រយល់ច្បាស់នូវឧត្តមគតិរបស់ខ្ញុំ ហើយប្រតិបត្តិតាមផ្លូវដែលខ្ញុំបានត្រាយទុកមក ។ ដោយវិចារណញ្ញាណនេះ ខ្ញុំចង់ឲ្យប្រជារាស្ត្ររក្សានូវសេចក្ដីមិនតក់ស្លុតជា ដាច់ខាត ហើយត្រូវយល់ថាថ្ងៃដែលគេចាប់ខ្ញុំ ទុកជាថ្ងៃនក្ខត្តឫក្ស, ខ្ញុំប្រាថ្នាចង់ឲ្យទុព្វលភាពរបស់យើងចាកចេញពីសន្ដានចិត្តក្នុងថ្ងៃនោះផង ។

បើគេចាប់ខ្ញុំ
រៀងចុះក្នុងសារព័ត៌មាននវជីវន (Naojivan)
(១៤-១១-១៩២០)

(មានត)

# ប្រវត្តិសាស្ត្រនៃស៊ីវិល្បៃខ្មែរបុរាណ

## លោកវ៉ាយ-ប៊ុក ក្រុមការ ប្រែរៀបរៀង

(តមក)

តាំងពីបឋមកាលនៃគ្រិស្តសករាជ, ឧបទ្វីប[១] ឥណ្ឌូចិននឹងកោះឥណ្ឌូណេស៊ី ជាប្រទេសដែលមានប្រជាជាតិឥណ្ឌូបានចេញចាកប្រទេសរបស់ខ្លួន មកតាំងទីលំនៅដើម្បីនឹងស្វែងរកមាស គ្រឿងទេសនឹងភោគ-ទ្រព្យផ្សេងៗ ។ ពួកនាវិកជនជាតិឥណ្ឌូមានចំនួនច្រើននាក់ បានធ្វើដំណើរមកកាន់ប្រទេសដែលមានប្រជាជាតិស៊ីវិល្បៃប្រហែលនឹងជាតិមួយ ឬជាតិបាតាក (Batak) នៅកោះស៊ូម៉ាត្រា ឬជាតិដាយ៉ាក (Dayak) នៅកោះបរណេអូក្នុងសម័យឥឡូវនេះ ជាហេតុឲ្យកើតព្រះរាជអាណាចក្រជាតិឥណ្ឌូជាច្រើន ហើយអ្នកដែលត្រួតត្រានៅក្នុងអាណាចក្រនីមួយៗ កាន់ទំនៀមទម្លាប់សាសនាតាមប្រទេសឥណ្ឌា ប្រើភាសាសំស្ក្រឹតជាផ្លូវសាសនា ។ ព្រោះហេតុដូច្នេះ បានជាកើតមានព្រះរាជអាណាចក្រកម្ពុជា, ចម្ប៉ា, ភូមា, ឧបទ្វីបជ្វា, ស៊ូម៉ាត្រា, ជវៈ, កោះបាលី ព្រមទាំងសៀម, លាវ ដែលបានទទួលវប្បធម៌ឥណ្ឌូអំពីជាតិមននឹងខ្មែរ ។

---

១ កោះដែលមានទឹកមិនព័ទ្ធជាប់ជុំវិញ ជាប់តែខ្លួយចំហៀង ហៅថា ឧបទ្វីប ។

ព្រះរាជអាណាចក្រខ្មែរ, ក្នុងបឋមកាល គឺក្នុងរវាងពាក់កណ្ដាលសតវត្សទី ៦ នៃគ្រិស្តសករាជ, ក្នុងកាលនោះ រដ្ឋកម្ពុជាដែលនៅពាក់កណ្ដាលទន្លេមេគុង ក្នុងភូមិភាគបាសាក់ បានតស៊ូរើខ្លួនចេញចាកអំណាចនិស្សរភាពនៃប្រទេសហ្វូណន៍ ។ ពាក្យថា "ហ្វូណន៍" នេះជាឈ្មោះអធិបទេសមួយ (Empire) ដែលអ្នកប្រវត្តិសាស្ត្រចិនបានសន្មតឡើងជាប្រទេសធំទូលាយកាន់ទំនៀមទម្លាប់ឥណ្ឌា ស្ថិតនៅខាងទិសទក្សិណក្នុងឧបទ្វីបឥណ្ឌូចិន ។

ក្នុងសម័យមុនអង្គរ (គឺតាំងពីពាក់កណ្ដាលសតវត្សទី ៦ ទៅដល់ចុងសតវត្សទី ៨), កាលប្រទេសកម្ពុជាស្ថិតនៅខាងទន្លេមេគុងខាងក្រោម, មហារាជក្នុងសតវត្សទី ៩ បានតាំងផ្ដើមកសាងព្រះរាជនិវេសស្ថាននៅខាងជើងបឹងទន្លេសាប, អង្គរជាព្រះរាជធានី ទើងបានស្ថាបនាឡើងក្នុងខាងចុងសតវត្សទី ៩ នៅដំបន់មួយមានភ្នំបាខែងនៅចំកណ្ដាល ហើយរាតទីក្រុងធំទូលាយ គឺត្រង់អង្គរធំសព្វថ្ងៃដែលមានប្រាសាទជាច្រើននោះឯង ។ ឯប្រាសាទទាំងនោះជាទីក្រុងកាលពីសតវត្សទី ១២ ។ សម័យអង្គរ គឺរាប់តាំងពីចុងសតវត្សទី ៩ រហូតដល់ពេលដែលលះបង់ព្រះរាជធានី គឺសតវត្សទី ១៥ ហៅថា សម័យអង្គរ ។

កន្លែងនេះ យើងនឹងប្រមូលវត្ថុធាតុដ៏សំខាន់ៗ សម្រាប់យកមកពណ៌នាពីរឿងស៊ីវិល្ស័យអង្គរ ជាកិច្ចពិសេសតទៅ ។

ត្រូវតែគោរពមនុស្សនីមួយៗ តាមកិត្តិយសសក្តិរៀង (A tout Seigneur, tout honneur) យើងត្រូវអធិប្បាយពីព្រះមហាក្សត្រិយ៍ជាមុនសិន ។ បើតាមលំនាំរបស់ធម្មជាតិ មុនដំបូង គួរពណ៌នាអំពីព្រះមហាក្សត្រិយ៍ដែលជាអម្ចាស់លើផ្ទៃក្រោម ជាមូលហេតុនៃអង្គការនយោបាយរបស់រដ្ឋ, ជាប្រភព (Source) ព្រមទាំងបុព្វហេតុនៃអំណាចគ្រប់យ៉ាង ។ តាមពិត ព្រះមហាក្សត្រិយ៍ជាព្រះមួយអង្គនៅលើផែនដីជាបុរសវិសេសគួរបូជាជាផ្លូវការដោយខ្ទេឡារិក ។ ប៉ុន្តែយើងមិនត្រូវគិតស្មានថា ព្រះមហាក្សត្រិយ៍ ដែលសោយរាជ្យនៅអង្គរជាព្រះមហាក្សត្រិយ៍សម្បូណ៌ផ្តាច់ការ ដោយមានព្រះរាជវិធានការព្រះដំរិះតែពីស្វេងរកគ្រឿងត្រេកត្រអាលក្នុងលោក, មិនមែនដូច្នោះទេ ព្រះមហាក្សត្រិយ៍ទាំងអស់អង្គសិងតែមានបច្ច័យទាក់ទងនឹងវិធានការខាងសន្តិវង្ស ព្រមទាំងច្បាប់ប្រពៃណីនយោបាយនឹងព្រះរាជចរិយា, ព្រះអង្គជាអ្នករក្សាទុកនូវច្បាប់និងរបៀបផ្សេងៗ ទ្រង់ជាអ្នកសម្រេចសេចក្ដីជាទីបំផុត ប្រសិនបើគូក្តីមិនសុខចិត្ត ។

(មានត)

# សព្ទបារាំងប្រែជាខ្មែរ

### របស់គណៈកម្មការវប្បធម៌

## ហ្លួងធិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួម

(តមក)

Sentier = ផ្លូវដើរ

Voie = ផ្លូវ

Dernière mode = សម័យថ្មី

(23-11-48)

(Le) mode = វិធី, បែប

(La) mode = ទំនើប

Style = បែប

Chic = ស្រស់

Goût = រសជាតិ

Elégant = សមសួន

Calendrier = ប្រក្រតិទិន

Almanach = មហាសង្ក្រាន្ត

Ephémeride = ឯកទិន

Agenda = ទិនានុលេខន៍

Mot exceptionnel = អញ្ញត្រស័ព្ទ

(30-11 48)

Collaboration = សហការ

Coopération = =

Bâtiment = អគារ

Objet = កម្មវត្ថុ

Institut national d'études juridiques et économiques = វិជ្ជាឋានបង្រៀនយុត្តិធម្មសាស្ត្រនិងសេដ្ឋសាស្ត្ររបស់ជាតិ

En laine = ឧណ្ណាម័យ

Oriflamme = ទង់សុវណ្ណផ្កាលា

(Le 3-12-48)

Prose = ពាក្យរាយ

Prose rythmée = ពាក្យក្រមង

Poésie = កវីនិពន្ធ

Vers = បាទ, ពាក្យកាព្យ

Poème = កាព្យនិទាន

Stance = គាថា

Strophe = បទ

Fable = រឿងល្បើក

Légende = រឿងព្រេង

Le poète (pour les figures) = អលង្ការកវី

Le poète (pour les idées) = អថិកវី

Epopée = ឦតិហាសៈ

(Le 7-12-48)

Ecriteau = ក្ដារប្រកាស

Marque = ត្រាសញ្ញា

Enseigne = យីហោ

Panneau = បណ្ណ

Facteur = កត្តា

Avenant = កិច្ចសន្យាបន្ថែម

Dénonciation d'un contrat = ការទំលាយកិច្ចសន្យា

Affiliation à la caisse des pensions de retraite = ការបញ្ចូលឈ្មោះក្នុងហិបរ៉ឺត្រែត

Titre universitaire = ឋានន្តរមហាវិទ្យាល័យ

(Le 10-12-48)

Institution = ការស្ថាបនា, ស្ថាប័ន

Construction = ការស្ថាបនា, សំណង់

Constructif = ស្ថាប័ក (= ប៉ុក)

Destruction = ការនិស្ថាបនា

Destructif = និស្ថាប័ក ( = បុ័ក )

Construire = ស្ថាបនា

Détruire = និស្ថាបនា

Instituer = ស្ថាបនា

(Le 17-12 48)

Collectif = ចរិកាប្រជួន

Bureau de Législation = ប៊ុយរ៉ូនីតិការ

Bureau de Matériel = ប៊ុយរ៉ូសម្ភារៈ

Bureau de Comptabilité = ប៊ុយរ៉ូបញ្ជី

Réquisition = កំណេណ្ឌ, សំបុត្រកំណេណ្ឌ

Proverbe = ភាសិត, ពាក្យទំនៀម

Devise = បាវចនា

Précepte = សិក្ខាបទ

Apophtegme = សុភាសិត

Attaquer = ប្រហារ

Armée Royale khmère = កងទ័ពខេមរភូមិន្ទ

Défilé = ការហែក្បួន

(Le 24-12-48)

(មានត)

# រឿងព្រេងភូមា

លោក សាន់-សារ៉ាត លេខានុការក្រសួងហិរញ្ញវត្ថុ

ប្រែចេញពីសៀវភៅកុងប៊ីរម៉ង (contes Birmans) របស់លោក ល្វី វ៉ុស្យុង (Louis Vossion)

ជាភាសាបារាំងមកជាខ្មែរ

(តមក)

## ៥ – ព្រាហ្មណ៍ទាំងបួន

“មិនត្រូវចង់បានទ្រព្យរបស់គេ”

ពាក្យថា “មិនត្រូវចង់បានទ្រព្យរបស់គេ” នេះ ជាសិក្ខាបទនៃចរិយាសាស្ត្រដែលមិនអាចរុះរើកែប្រែបាន ជាសិក្ខារបស់ជនដែលមានបំណងចង់លើកតំកើងខ្លួនឲ្យបានដល់សេចក្ដីចម្រើនដ៏ខ្ពង់ខ្ពស់ ឬយ៉ាងតិចណាស់ត្រឹមសេចក្ដីចម្រើនណាដែលមនុស្សយើងក្នុងលោកនេះអាចទទួលបាន ៗ ធម្មតាមនុស្ស ទោះជាអ្នកកាន់ព្រះពុទ្ធសាសនាបេះដូងជ្រៅជ្រះយ៉ាងណាក៏ដោយ ក៏មិនអាចមានសន្តិចរិយាពិតប្រាកដបាន បើអ្នកនោះមិនព្រមលះបង់សេចក្ដីបំណងផ្សេង ៗ ក្នុងលោកចេញអំពីសន្តានរបស់ខ្លួនទេ ៗ ដូចមាននិទានជាឧទាហរណ៍បង្ហាញឲ្យឃើញជាក់ស្ដែងតទៅនេះ ÷

ក្នុងសករាជព្រះពុទ្ធ ដូម៉ានៅ ទី ១៣ ៗ នៅក្នុងស្រុកតង្គតនាគោ (Tangatanago) មានព្រាហ្មណ៍បួននាក់ មានឈ្មោះល្បីល្បាញទូទៅក្នុង

ប្រទេស ថាជាអ្នកចេះខាងសិល្បសាស្ត្រ ។ ព្រាហ្មណ៍ទាំងបួននាក់នេះ បានចងស្ពានមេត្រីយ៉ាងជិតស្និទ្ធនឹងគ្នា ។ បណ្ដាព្រាហ្មណ៍ទាំង ៤ នោះ ព្រាហ្មណ៍ម្នាក់ៗ មានមាសចំនួន ១០០ ដំឡឹង ទុកសម្រាប់ត្រូវការផ្សេងៗ ដើម្បីកុំឲ្យព្រួយនឹងការខ្វះខាតគ្រឿងប្រដាប់ប្រដាប្រើប្រាស់នឹងការអត់អាហារក្នុងពេលដែលខំប្រឹងធ្វើសមណធម៌ ។ ព្រាហ្មណ៍ទាំងបួននាក់នៅរួមសុខទុក្ខជាមួយគ្នា បរិភោគអាហារជាមួយគ្នា ។ ឯអាស្រមនៃព្រាហ្មណ៍ទាំង ៤ នោះ ជាទីគួរដល់ការអប់រំចិត្ត ព្រោះមានម្លប់ឈើត្រឈៃហើយនៅឆ្ងាយពីផ្លូវថ្នល់ធំ ទាំងឆ្ងាយសូរសព្ទផ្សេងៗ ។

មានថ្ងៃមួយ ព្រាហ្មណ៍ទាំងបួននាក់បាននាំគ្នាទៅមុជទឹកឯជ្រោះដែលមានទឹកហូរចេញតាមបាតត្រកួន ឆ្ងាយអំពីអាស្រមរបស់ខ្លួន ហើយបានព្រមព្រៀងទុកមាសជាមួយគ្នា ក្នុងកន្លែងមួយដ៏កំបាំងប្របគល់ឈើ ដើម្បីកុំឲ្យពិបាកក្នុងដំណើរតាមផ្លូវ ហើយសង្ឃឹមថា ប្រាកដជាមិនបាត់ លុះកាលណាត្រឡប់មកពីមុជទឹកនឹងយកវិញ ។ បណ្ដាព្រាហ្មណ៍ទាំងបួននោះ, ព្រាហ្មណ៍ម្នាក់នៅក្មេងជាងគេ, ព្រាហ្មណ៍ចាស់ ៣ នាក់ប្រើព្រាហ្មណ៍ក្មេងនោះឲ្យយកមាសទាំង ៤០០ ដំឡឹងនោះទៅកប់ទុក ។

ឯព្រាហ្មណ៍កម្លោះ លុះបានមាសដល់ដៃ ក៏កើតគំនិតអាក្រក់ឡើងក្នុងខ្លួនភ្លាម ប៉ីដូចដើមឫស្សីដែលត្រូវដីមានជីជាតិ បានយកមាសតែ ៣០០ ដំឡឹងទៅកប់ក្នុងរណ្ដៅ ឯមាសរបស់ខ្លួនយកទៅកប់ទុកក្នុងទីដទៃ

ឆ្ងាយពីទីនោះបន្តិច ៗ ព្រាហ្មណ៍កម្មោះសង្ស័យថា "តែកាលណាត្រឡប់មកវិញ មិត្តរបស់អញទាំង៣នាក់មុខជាគ្មានសង្ស័យលើរូបអញទេ មុខជាគេនឹកស្មានថា មានចោរណាមួយចូលមកលួចពុំខាន, រួចអញនឹងសុំឲ្យគេចែកមាសដែលនៅសល់ទាំងប៉ុន្មានជាបួនភាគស្មើគ្នា, កាលបើយ៉ាងនេះ អញនឹងបានមាសកើតឡើងទៀត ហើយនឹងយកទៅលក់ស៊ីចាយលេងសប្បាយផ្សេងៗ ឯទីក្រុងជិតខាងណាមួយ" ៗ ព្រាហ្មណ៍កម្មោះដែលមានគំនិតទុច្ចរិតយ៉ាងនេះ ព្រោះចិត្តគាត់ដេកត្រាំក្នុងផ្លូវអកុសលចំណែកខាងសីលដែលគាត់ធ្វើៗ ទាំងទទឹងចិត្ត ៚

លុះត្រឡប់មកពីមុជទឹកវិញ ព្រាហ្មណ៍កម្មោះទៅឯកន្លែងដែលលាក់មាស, ក្រោយបន្តិចមក គេឃើញគាត់រត់ម្រង់ទៅផ្ទះ ហើយលើកដៃក្រវីស្រែកថាមាសឃើញតែ ៣ ដុំ គឺដុំដែលធ្វើអំពីសំពត់ទេសឯកសប៉ុណ្ណោះទេ, ឯដុំរបស់គាត់បាត់ ការណ៍នេះជាអស្ចារ្យចំឡែកណាស់; គាត់និយាយឲ្យគេចែកមាសដែលនៅសល់ឲ្យស្មើគ្នាទាំងអស់ដើម្បីជួយគាត់ដោយសារទ្រព្យរបស់គាត់បាត់នេះ ៗ ឯព្រាហ្មណ៍ទាំងបីនាក់នឹកសង្ស័យនឹងការសុំចែកមាសនេះពន់ពេក ហើយមិនសុខចិត្តយល់ព្រមតាមសោះ ដោយគិតឃើញថា "ព្រាហ្មណ៍កម្មោះនេះបានទុកដាក់មាសនឹងដៃឯង អាស្រ័យហេតុនេះរាត្រីតែដឹងកិច្ចការទាំងអស់, មួយទៀតខ្លួនទាំងអស់គ្នាក៏សុខចិត្តក្រផង" ៗ ព្រាហ្មណ៍ទាំងបីនាក់និយាយ

ទៅកាន់ព្រាហ្មណ៍កម្លោះថា "អ្នកឯងនេះ យើងបានដាក់ភារៈឲ្យទុកមាស ហេតុអ្វីក៏មិនដឹងជាមាសរបស់អ្នកបាត់ទៅឯណា ហេតុនេះយើងទាំងអស់គ្នាមិនត្រូវការទទួលគ្រោះថ្នាក់ឥតប្រយោជន៍ជាមួយនឹងអ្នកឯងទេ" ។

តាមទំនៀមស្រុក, ព្រាហ្មណ៍ទាំងបួននាក់នាំគ្នាទៅប្ដឹងលោកសុភា នៃភូមិភាគនោះ ដើម្បីនឹងជំរាបលោកតាមដំណើរទំនង ហើយសុំឲ្យលោកវិនិច្ឆ័យកាត់សេចក្ដីឲ្យ ។ ឯលោកសុភាមានចិត្តងឿងឆ្ងល់នឹងរឿងចំឡែកនេះណាស់ ប៉ុន្តែលោកមិនរវល់ធ្វើអង្កេតវែងឆ្ងាយ; ដើម្បីឲ្យជ្រះស្រឡះផុតពីលោកឆាប់ទៅ លោកបានឲ្យចែកមាសដែលនៅសល់ ជា ៤ ភាគស្មើគ្នាឲ្យទៅគូក្ដីទាំងបួន ។ ព្រាហ្មណ៍ទាំងបី មានសេចក្ដីឈឺចិត្តណាស់ ហើយចង់ដឹងសេចក្ដីពិតផង មិនយល់ព្រមធ្វើតាមពាក្យលោកសុភានោះឡើយ ត្រឡប់នាំគ្នាទៅឯចៅហ្វាយខេត្ត ។ លោកចៅហ្វាយខេត្ត បានបញ្ជូនខ្លួនព្រាហ្មណ៍ទាំង ៣ នាក់នោះព្រមទាំងព្រាហ្មណ៍កម្លោះទៅសាលាយុត្តិធម៌របស់ព្រះមហាក្សត្រិយ៍ ។ ព្រះមហាក្សត្រិយ៍លុះបានទ្រង់ព្រះសណ្ដាប់ដោយហ្មត់ចត់ហើយ ទ្រង់ក៏យល់តាមសេចក្ដីវិនិច្ឆ័យរបស់លោកសុភាក្នុងភូមិភាគនោះ ។ កាលណាព្រះមហាក្សត្រិយ៍ទ្រង់ឈប់មានព្រះរាជឱង្ការហើយ ព្រាហ្មណ៍ទាំងបីនាក់នៅស្ងៀមមួយស្របក់ ហើយមើលមុខគ្នាទៅវិញទៅមក ដោយឥតនិយាយអ្វីសោះ រួចស្រាប់តែក៏លាន់ឮរជៀវឡើង; ដល់ក្រោយមក

ព្រាហ្មណ៍ដែលចាស់ជាងគេ បានទូលទាស់នឹងព្រះរាជបំណងនេះឡើងៗ ព្រះរាជាទ្រង់មិនទាន់យល់រឿងដ៏ចំឡែកនេះដោយជាក់ច្បាស់ ទ្រង់ក៏មានព្រះរាជបំណងចង់ឲ្យមានការអង្កេតមួយយ៉ាងពិស្ដារ ហើយហ្មត់ចត់ផង ទើបទ្រង់ត្រាស់ហៅកុង្សីយ៍ទីមួយមក រួចទ្រង់បង្គាប់ឲ្យរករឿងនេះឲ្យឃើញច្បាស់ឡើង ដោយទ្រង់កំហែងដាក់កំរិតថា បើក្នុងរវាង ៧ ថ្ងៃទៀត លោកកុង្សីយ៍រករឿងនេះមិនឃើញទេ ទ្រង់នឹងហូតងារចេញ ទុកជាជាអ្នកគ្មានសេចក្ដីឈ្លាសវៃ ក្នុងកិច្ចការដ៏ឧត្ដមរបស់ខ្លួន ៗ

លោកកុង្សីយ៍ដឹងថា ព្រះបន្ទូលរបស់ស្ដេចជាពាក្យស័ត្យ, ហើយលោកបានហៅព្រាហ្មណ៍ទាំងបួននាក់មកសួរម្នាក់ម្ដងៗ ដើម្បីធ្វើអង្កេតការណ៍នេះឲ្យបានហ្មត់ចត់ ៗ ប៉ុន្តែលុះលោកខំធ្វើអង្កេតណាស់ទៅ រឹតតែប្រទះឃើញរឿងនេះជំពាក់ស្មុកស្មាញក្នុងខួរក្បាលរបស់លោកឡើងទៀត រហូតដល់រាត្រីគ្របដណ្ដប់ផ្ទៃត្រីស្ថានរបស់លោកហើយ លោកក៏នៅតែពិចារណារឿងនេះមិនឃើញដដែល ៗ ក្នុងពេលនោះ បុត្រីដ៏ប្រសើររបស់លោកឈ្មោះនាង សង់ដាកុមារី (Tsanda Kommari) ដែលស្រឡាញ់លោកជាទីបំផុត បានសង្កេតឃើញសេចក្ដីទុក្ខរបស់លោក ៗ នាងអង្គុយរម្យទំបក់ផ្លិតជូនលោក ហើយសួរថា "លោកឪពុក! ហេតុដូចម្ដេច បានជាកើតទុក្ខព្រួយម៉្លេះ?" ៗ លោកឆ្លើយវិញថា "កូនសំឡាញ់មាសឪពុក! ឯហេតុដែលសង្កត់សង្កិនចិត្តរបស់ឪពុកនេះ គឺស្ដេចទ្រង់

បង្គាប់ឲ្យឪពុកបំភ្លឺរឿងដ៏ពិបាកមួយ របស់ព្រាហ្មណ៍ទាំងបួននាក់, រួចបើសិនណាក្នុងរវាង ៧ ថ្ងៃនេះ ឪពុកធ្វើការនេះមិនបានសម្រេចទេ ឪពុកនឹងរលំពីកិត្តិយសនឹងពីថ្នាក់របស់ឪពុកសព្វថ្ងៃនេះហើយ" ថាហើយលោកនិយាយរឿងយ៉ាងច្បាស់លាស់ប្រាប់នាង ។ កូនស្រីឆ្លើយថា "សូមលោកឪពុកកុំខ្លាចឲ្យសោះ កូនធានាអះអាងរករឿងនេះឲ្យឃើញមុនថ្ងៃទី ៧ នេះ ឲ្យដឹងតើព្រាហ្មណ៍ណាបានលួចគេ ប៉ុន្តែសុំឲ្យលោកឪពុកសង់រោងបណ្តោះអាសន្នមួយឲ្យសមរម្យ ធ្វើអំពីឫស្សីណាដែលស្រាលៗ សង់នៅកៀនស្ងាត់មួយក្នុងសួនច្បារ រួចខ្ញុំហ៊ានសន្យាថាការណ៍នេះនឹងបានសម្រេចជាប្រាកដមិនខាន" ។

លោកកុង្សីយ៍បានបង្គាប់ឲ្យជាងធ្វើរោងតាមបំណងនាងដោយរួសរាន់, រួចបន្តិចក្រោយមក រោងស្រាលមួយក៏កើតឡើងក្នុងទីសួនច្បារនោះត្រង់កន្លែងដែលនាងបង្ហាញ ។ នាងឲ្យព្រាហ្មណ៍ម្នាក់ៗឈរនៅជ្រុងរោងមួយៗគ្រប់ជ្រុងទាំងបួន ហើយនាងអង្គុយចំកណ្តាល ជាមួយស្រីបំរើរបស់នាងម្នាក់ នៅលើកន្ទេលដែលមានកម្រាលយ៉ាងរលើបរលង់ ។

លុះដល់ពេលយប់, ផ្ទៃសួនច្បារទាំងមូលក៏ភ្លឺត្រចះត្រចង់ដោយរស្មីនៃព្រះច័ន្ទ, កាលសូរសព្ទទាំងពួងបាត់ស្ងប់ស្ងាត់សូន្យឈឹង នាងសុំឲ្យព្រាហ្មណ៍ទាំងអស់និទានរឿងប្រាជ្ញប្រាយផ្សេងៗ ដែលខ្លួនចេះចាំជាងគេ ទោះជារឿងទាំង ១៨ នៃលោកយើងនេះក្តី ឬរឿងសាវតារ

រឿងដំបូន្មានណាក្ដី ឬ រឿងបរមត្ថវិជ្ជា ដែលជាវិជ្ជាសម្រាប់អ្នកប្រាជ្ញ ទីងអ្នកកាន់សាសនាក្ដី ។ ព្រាហ្មណ៍ទាំងបួននាក់លុះបានឮដូច្នោះហើយ ក៏ឱនក្បាលដោយឥតឆ្លើយអ្វីមួយមាត់សោះ ។ ក្រោយមក ព្រាហ្មណ៍ដែលចាស់ជាងគេ ឆ្លើយឡើងដោយអឹមអៀមថា "នាង! យើងស្ដាយណាស់ ចំពោះកិច្ចដែលយើងនឹងធ្វើតាមបំណងរបស់នាងមិនកើត ព្រោះយើងខ្លាចក្រែងមានកំហុស, ដ្បិតបណ្ដាពួកយើងទាំងអស់នេះ មានម្នាក់មានកិរិយាអាក្រក់ ប៉ុន្ដែយើងមិនហ៊ានចាប់ផ្ដាក់ទេ, បើព្រាហ្មណ៍អាក្រក់នេះ នៅតែមានកិរិយាមិនស្អាតមិនល្អដរាបណា ដរាបនោះ យើងមិនអាចនៅសាងធម៌ព្រះពុទ្ធជាមួយបានឡើយ, ហេតុនេះ មានតែព្រះនាងនេះហើយ ដែលចេះដឹងជ្រៅជ្រះ មានកេរ្ដិ៍ឈ្មោះល្បីល្បាញខាងបរមត្ថវិជ្ជានឹងខាងចរិយាសាស្ដ្រ ទាំងមានវ័យនៅក្មេងត្រឡាំងយ៉ាងនេះ ទើបអាចចេះនិយាយរឿងផ្សេងៗ បាន" ។ នាងឆ្លើយថា "ទេលោក, ខ្ញុំជាស្រីល្ងង់ដូចស្រីឯទៀតទាំងពួងដែរតើ ខ្ញុំនេះមិនអាចប្រៀបផ្ទឹមនឹងលោកបានឡើយ ហើយខ្ញុំមិនអាចនិយាយឲ្យបានល្អក្បោះទេចំពោះមុខលោកទាំងអស់ ដែលខ្ញុំទុកដូចជាគ្រូអាចារ្យរបស់ខ្ញុំទេ, ប៉ុន្ដែបើលោកមានបំណងចង់ឲ្យខ្ញុំនិយាយ ខ្ញុំក៏សុខចិត្តនិទានរឿងមួយជូនលោកស្ដាប់ដែរ" ។ ព្រាហ្មណ៍ទាំងបួនក៏ធ្វើសញ្ញាថា យល់ព្រមឲ្យនាងនិទានរឿង ដូចមានតទៅនេះ ៖

(មានត)

# រឿងសាមកុក

កណ្ឌទី ៥

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

អ្នកសៀវនឹងបណ្ដាចៅហ្វាយខែត្រទាំងអស់ក៏មិនបានតបថាប្រការម្ដេច ៗ ប៊ូឆ្វនឹកតូចចិត្តណាស់គិតរំពឹងថា ពួកទាំងនេះមុខជាប្រែចិត្តគិតដកថយពីគ្នាជាប្រាកដហើយ ដែលនឹងសង្ឃឹមយកជាគំនិតចិត្តមួយផងគ្នាឃើញជាមិនបាន, ប៊ូឆ្វខឹងណាស់ចុះដើរចេញទៅចាត់ចែងទាហាន ហើយលើកត្រឡប់ទៅស្រុកអេងជីវ, បណ្ដាចៅហ្វាយខែត្រទាំងអស់ក៏ត្រឡប់ទៅកាន់ទីដំនុំវិញ ៗ

ឯកង់ស៊ុនចាននិយាយទៅនឹងឡេវពី គួនអ៊ូ តៀវហ៊ុយថា អ្នកសៀវនេះដែលនឹងគិតការណ៍ធំទៅនោះមិនបានទេ យូរទៅនឹងមានអន្តរាយ បើយើងតាមផងនឹងបានតែសេចក្ដីលំបាក ដូច្នេះ យើងត្រូវនាំគ្នាទៅស្រុកវិញល្អជាង ៗ

ឡេវពី គួនអ៊ូ តៀវហ៊ុយ ឃើញត្រូវផងក៏បបួលគ្នាលើកពលទាហានត្រឡប់ទៅស្រុកផេងង្ហួនគួន, ឡេវពីក៏លាចូលទៅនៅថែរក្សាស្រុក, កង់ស៊ុនចាន ក៏លើកហួសទៅស្រុកប៉ាក់ប៉េង ៗ

ឯឡៅតាយជាប់ស្បៀងអាហារនឹងតាក់ការឲ្យសេនាទាហានពុំគ្រប់គ្រាន់ បានឲ្យបំរើទៅនិយាយខ្ចីស្បៀងអាហារពីតៀវមៅៗមិនព្រមឲ្យ, ឡៅតាយខឹងណាស់ ដល់ពេលកណ្ដាលយប់ ក៏លើកទាហានទៅលុកបន្ទាយតៀវមៅ សម្លាប់តៀវមៅស្លាប់, ភ្លឹងពេលនោះ ពួកទាហានតៀវ-មៅ នាំគ្នាមកចូលនៅនឹងឡៅតាយទាំងអស់ ។ អ្នកសៀវឃើញហៅ-ហ្វាយខែត្រទាំងអស់គ្នា បែកខ្វែកចិត្តប្រែគំនិតទៅដោយខ្លួន ខ្លះលើកទាហានទៅវិញដូច្នោះ, អ្នកសៀវក៏ឃុំទាហានលើកទៅស្រុកហូឡាយ, ហៅហ្វាយខែត្រក្រៅពីនោះ លើកទាហាននាំវិលទៅខែត្រខណ្ឌរៀងខ្លួនៗ ឯឡៅតៀវហៅហ្វាយស្រុកកេងជីវនោះ ជាពូជព្រះរាជវង្សព្រះហៅហាន គួច្ឆ មានទីប្រឹក្សា ៧ នាក់ ឈ្មោះតាន់សៀង ពួកស្រុកឃីឡាំ ១ ខុងលិប ពួកស្រុកឡោកុក ១ ហ្វូនខុង ពួកស្រុកពុតហៃ ១ តៀវលី ពួកស្រុកសានយ៉ុង ១ តៀវខៀម ពួកស្រុកសានយ៉ុង ១ ង៉ីមទិត ពួកស្រុកឡាំយ៉ុង ១ ហ្វូនហុង ពួកស្រុកឃីឡាំ ១ ទាំង ៧ នាក់នេះជាកៀនស៊ុខស្លាលនឹងឡៅតៀវមកពីដើម; នៅមានសេនាទាហានឯក ៣ នាក់ទៀតឈ្មោះកេងលៀង ១ កេងអ្វូត ១ ឈ្វម៉ ១ ទាំង ៣ នាក់នេះជាពួកស្រុកអៀងប៉េង ។

ឡៅតៀវកាលបានដឹងហេតុតាមសេចក្ដីសំបុត្រ ដែលអ្នកសៀវឲ្យក៏ចាត់ប្រើកេងអ្វូតនឹងឈ្វម៉ឲ្យលើកទាហាន ១ មុឺន ទៅស្កាត់ផ្លូវដែលស៊ុនកៀនលើកមកនោះ, លុះជួបប្រទះទ័ពគ្នាហើយ កេងអ្វូតក៏ចេញទៅឈរ

ពីមុខទាហានទាំងពួង ។ ស៊ិនកៀនស្រែកសួរកេងអួតថា អ្នកលើកទាហានមកស្កាត់ផ្លូវយើងទុកដូច្នេះ តើអ្នកនឹងប្រាថ្នារបស់អ្វី? ។ កេងអួតតបថា ខ្លួនអ្នកជាខ្ញុំរាជការព្រះចៅហៀនគេ បានទាំងស៊ីបៀវត្សដរាបមក ហេតុអ្វីអ្នកនាំយកត្រាផ្ទាក់សម្រាប់ព្រះមហាក្សត្រមកនៅនឹងខ្លួន អ្នកយកទៅធ្វើអ្វី អ្នកចូរយកត្រានោះមកប្រគល់ឲ្យយើងជាប្រញាប់ យើងនឹងបាននាំចូលទៅថ្វាយព្រះចៅហៀនគេ បើអ្នកមិនព្រមឲ្យទេ យើងក៏មិនបើកផ្លូវឲ្យទៅ ។ ស៊ិនកៀនបានស្តាប់ហើយខឹងណាស់ ទើបប្រើអ៊ុយកាយឲ្យចេញទៅតយុទ្ធនឹងកេងអួត, ពេលនោះឈ្មួម៉បរសេះស្ទុះទៅមុខកេងអួតប្រយុទ្ធនឹងអ៊ុយកាយបាន ៧ ស្នៀត អ៊ុយកាយយកដំបងដែក ៤ ជ្រុងបុកត្រូវដើមទ្រូងឈ្មួម៉ ក៏ញាក់សេះរត់ ស៊ិនកៀនក៏ថែមដេញចាក់កាប់ទាហានឈ្មួម៉ទៅដល់មុខស្រុកកេងជីវ ហើយស្រាប់តែឮសំឡេងគងឃោះលើកំពូលភ្នំ ស៊ិនកៀនក្រឡេកទៅឃើញឡៅពៀវលើកទាហានមកជាច្រើនព័ទ្ធជុំវិញខ្លួន ក៏មានសេចក្ដីភិតភ័យណាស់ ។ ស៊ិនកៀនឧនគំនាប់ឡៅពៀវហើយថា លោកជឿស្ដាប់តែសំបុត្រអូនសៀវហើយលើកទាហានមកធ្វើការទាំងនេះ ហាក់បីដូចជាមិនអាណិតអាសូរដល់ខ្ញុំសោះ ។ ឡៅពៀវសួរថា ដែលអ្នកនាំយកត្រាសម្រាប់រាជ្យមកនេះនឹងគិតដណ្ដើមយករាជសម្បត្តិឬ? ។ ស៊ិនកៀនឆ្លើយថា បើខ្ញុំបានយកត្រាសម្រាប់រាជ្យមក ដូចអូនសៀវឲ្យដំណឹងមែន សូមឲ្យខ្ញុំស្លាប់

ដោយគ្រឿងសស្ត្រាវុធផ្សេងៗចុះ ៗ ឡេវ៉ាពៀរឆ្លើយថា បើអ្នកនឹងចង់ឲ្យយើងអស់សង្ស័យ ចូរហៅទាហានទាំងអស់របស់អ្នកមកឲ្យយើងត្រួតពិនិត្យមើល ទើបយើងជឿជាក់ប្រាកដ ៗ ស៊ុនកៀនខឹងណាស់ឆ្លើយតបថា យើងបានស្បថស្បាន់តម្រង់ខ្លួនហើយ នៅតែមិនជឿទៀត បើអ្នកមានថ្វីដៃខ្លាំងពូកែយ៉ាងណា ចូរមកល្បងគ្នាចុះ ៗ ឡេវ៉ាពៀរបានស្តាប់ដូច្នោះ ក៏ក្អេងឆ្លើជាលើកពលថយក្រោយទៅវិញ, ស៊ុនកៀនបំផាយសេះដេញទៅដល់ដើងកំសងខាងផ្លូវ, ឯទាហានឡេវ៉ាពៀរដែលបង្កប់នៅទីនោះស្ទុះចេញមកទាំងសងខាង, ទទួលឈ្មួមទឹងកេងអ្នួត ដែលរត់ដោយបាញ់ដៃទ័ពស៊ុនកៀននោះ បរសេះនាំទាហានមកពីក្រោយថែមទៀតព្រួតព័យផ្ទប់ប្រសព្វគ្នា, ឡេវ៉ាពៀរក៏បរពលព័យប្រសព្វមកពីមុខទៀត ស៊ុនកៀនទាល់ច្រកក៏ពព្យាំងទាំងសងខាងមុខក្រោយ, អ៊ុយកាយនឹងទៀដៅ ហានតុង ឃើញខ្ទបខាតទាហានច្រើនណាស់ ព្រោះទាហានឡេវ៉ាពៀរឡោមព័ទ្ធជាប់ស៊ុនកៀននៅកងបំណោមទ័ព ក៏ស្ទុះទំលុះទំលាយទៅជួយហើយនាំយកស៊ុនកៀនចេញមកបាន ស្រូតលើកទាហានតម្រង់ទៅស្រុកកាំងតាំង ៗ ចាប់តាំងពីនោះមក ឡេវ៉ាពៀរនឹងស៊ុនកៀន ក៏មានសេចក្តីគំនុំគុំគួនព្យាបាទគ្នាជាប់កុងចិត្ត ៗ

# កណ្ឌទី ៦

ចាប់តាំងពីហានគីបបួលអួនសៀវទៅច្បាំងយកស្រុកគីជីវ រៀងរហូតដល់អងអ៊ុន និយាយលួងលោមនាងគៀវលៀនជាកូនចិញ្ចឹម ឲ្យទៅធ្វើប្រពន្ធតាំងតុះផង លីបោផង ដើម្បីនឹងឲ្យអ្នកទាំង ២ នេះទាស់ទែងខ្វែងគំនិតគ្នា

---

ខណៈកាលអួនសៀវដែលលើកសេនាយោធាទៅស្រុកហូឡាយនោះ ក៏ដាច់ស្បៀងអាហារអស់រលីង, លុះដំណឹងនេះជ្រាបដល់ហានហុក ចៅហ្វាយស្រុកគិជីវៗ ហានហុកក៏ចាត់មនុស្សឲ្យនាំស្បៀងទៅជូនអួនសៀវ ៗ ពេលនោះ ហាងគីនិយាយនឹងអួនសៀវថា បណ្ដាមនុស្សទាំងអស់ក៏បានដឹងច្បាស់ប្រាកដថាលោកនេះពូជនាហ្មឺនតៗ មកពីដើម ដែលលោកមកធ្វើការទំនុកបំរុងផែនដីសម័យនេះ មិនគួរនឹងមកអង្គុយចាំពិសាដោយគេបញ្ជូនស្បៀងអាហារមកឲ្យនោះសោះ ប្រសិនជាមិនមានគេបញ្ជូនមកជូនលោកៗ ក៏មានសេចក្ដីលំបាក ការណ៍នេះខ្ញុំឃើញថាស្រុកគីជីវ មានមនុស្សអ្នកមានទ្រព្យសម្បត្តិ ទាំងស្រូវអង្ករចំណីត្រីសាច់ក៏សឹងតែបរិបូណ៌មិនខ្វះខាត សុំឲ្យលោកលើកសេនាទាហានទៅវាយយកស្រុកគីជីវចុះ ដល់វាយបានហើយលោកត្រូវនៅកាន់កាប់ស្រុកនោះតទៅ បើលោកនឹងប្រាថ្នាគិតការអ្វីជាធំក៏នឹងបានសម្រេចតាមប្រាថ្នា ៗ អួនសៀវឆ្លើយតបថា យើងក៏បានរិះគិតដូច្នេះដែរ តែថាមិនទាន់មានឱកាសនឹងធ្វើបានៗ ជាបន្ទន់នៅស្ងៀមសិន ៗ ហាងគីថា បើលោកគិតជាប្រាកដ

ត្រូវមានសំបុត្រសម្ងាត់ទៅដល់កង់ស៊ុនចាន ឲ្យលើកទ័ព ហានចូលវាយស្រុកគីជីវ ១ ផ្លូវ ចំណែកលោកលើកទៅវាយប្រសព្វ ១ ផ្លូវទៀត បើបានស្រុកនោះហើយ សុំបែងចែកទ្រព្យរបស់នឹងមនុស្សចំណុះស្រុកឲ្យកង់ស៊ុនចានពាក់កណ្ដាលចុះ នោះបើកង់ស៊ុនចានលើកទ័ពហានទៅជួយវាយលើកនេះ, ឯហាន់ហុកចៅហ្វាយស្រុកនោះជាមនុស្សមិនចេះគិតអ្វីសោះ គង់នឹងមានសំបុត្រមកដល់លោកឲ្យលើកទ័ពបានទៅជួយលោកក៏នឹងបានស្រុកគីជីវដោយងាយមិនព្រួយបារម្ភ ។ អួនសៀវឃើញត្រូវ ទើបតែងសំបុត្រការសម្ងាត់ប្រាប់ទៅកង់ស៊ុនចានតាមគំនិតរបស់ហានគី ។

សម័យនោះ កង់ស៊ុនចានបានទទួលសំបុត្រអួនសៀវមើលដឹងសេចក្ដីហើយក៏មានចិត្តត្រេកអរពន់ពេក ទើបធ្វើសំបុត្រតបទៅអួនសៀវវិញ ប្រាប់ពេលកំណត់ដែលនឹងលើកទ័ពហានទៅវាយស្រុកគីជីវនោះ ។ អួនសៀវបានដឹងសេចក្ដីសំបុត្រនោះហើយ ក៏ចាត់បំរើម្នាក់ឲ្យនាំសំបុត្រ ១ ច្បាប់ទៅប្រាប់ហាន់ហុកចៅហ្វាយស្រុកគីជីវថា ឥឡូវនេះកង់ស៊ុនចានមានសំបុត្រមកប្រឹក្សាថា នឹងលើកទ័ពហានមកវាយយកស្រុកគីជីវហើយ ។ ហាន់ហុកទទួលសំបុត្រហើយក៏ហៅទីប្រឹក្សា ឈ្មោះស៊ុនស៊ុមនឹងស៊ុនប៉េងមកពីគ្រោះថា ឥឡូវកង់ស៊ុនចានមុខជានឹងលើកទ័ពហានមកវាយស្រុកយើងហើយ តើយើងនឹងគិតដូចម្ដេច? ។

ស៊ុនស៊ុមឆ្លើយថា ដែលកង់ស៊ុនបាននឹងលើកទាហានមកវាយស្រុកយើងនេះ យើញថានឹងលើកមកច្រើនណាស់ ហើយទៀតក្ដី កួនអ៊ូ គៀវ ហ៊ុយក៏គង់នឹងមកផង ទាហានរបស់យើងឃើញជាតស៊ូនឹងគេមិនបាន ឯអ្នកសៀវក៏ប្រកបទៅដោយសតិបញ្ញា មានទាហានឯកនឹងទាហានទ្បើវក៏ច្រើន បើដូច្នេះ សុំឲ្យលោកមានសំបុត្រទៅអញ្ជើញអ្នកសៀវមកនៅឈរក្សាស្រុកយើងចុះនឹងបានជួយការពាររក្សាគ្នាតទៅ អ្នកសៀវក៏គង់មានសេចក្ដីមេត្តាដល់លោកខ្លះ ឯកង់ស៊ុនបានក៏គង់មិនហានមកញាំញីស្រុកយើងព្រោះក្រែងខ្លាចអ្នកសៀវ ។

ហានហ៊ុកស្ដាប់ហើយឃើញត្រូវផង ក៏តែងសំបុត្រ ១ ច្បាប់ឲ្យតួនគីនាំទៅជូនអ្នកសៀវតាមពាក្យស៊ុនស៊ុម ។ ពេលនោះ គេងប៊ូដំពបហានហ៊ុកថា អ្នកសៀវនោះជាមនុស្សទាល់គំនិតហើយ ដែលនៅគង់ទ្រង់តាំងខ្លួនចិញ្ចឹមទាហានសព្វថ្ងៃនេះបាន ដោយអាស្រ័យស្បៀងអាហារដែលលោកបញ្ជូនទៅឲ្យ ប្រមាប៉ីដូចជាទារក បើមាតាមិនឲ្យទឹកដោះបៅហើយ ក៏មានតែសេចក្ដីយំសោកជាទុក្ខដោយការស្រេកឃ្លាន, បើលោកនឹងឲ្យអ្នកសៀវមកជួយរក្សាស្រុកជាប្រធាន ក៏ដូចជាចាប់ខ្លាទៅលែងក្នុងហ្វូងចៀមស្រែ គង់នឹងមានភ័យអន្តរាយដល់សត្វទាំងនោះ, ការណ៍នេះសូមលោកត្រិះរិះមើលតាមសមគួរសិន ។ ហានហ៊ុកតបថា ខ្លួនយើងពីដើមដែលនឹងបានធ្វើជានាហ៊ុនជាប់មកនោះ ក៏ព្រោះតែអ្នកជួយឧបត្ថម្ភនាំសេចក្ដីគុណតាប់ឲ្យកើតឡើង ទើបយើងបានមកធ្វើចៅ-

ហ្វាយស្រុកនេះ, យើងក៏ឃើញថាអ្នកសៀវមានសតិបញ្ញាល្អជាងយើង, ម្យ៉ាងទៀតចាស់បូរាណមានថាទុកមកថា "បើអ្នកឯណាមានសតិបញ្ញា ត្រូវឲ្យអ្នកល្ងង់ៗស្ដាប់គោរពកោតខ្លាច ទើបអាចរក្សាសេចក្ដីសុខបាន" ដែលអ្នកមកយល់ទាស់ឲ្យខុសនឹងពាក្យចាស់បូរាណដូច្នេះ យើងមិនយល់ព្រមផងទេ ។

គេងប៊ូបានឮដូច្នោះក៏ដកដង្ហើមធំហើយនិយាយថា ស្រុកគីដីវនេះគង់នឹងសាប់សូន្យជាដាច់ប្រាកដ ។ គេងប៊ូនឹងនាហ្មឺនចំនួន ២៣ នាក់ក៏លាឆ័រចេញពីរាជការ ។ គេងប៊ូបាននាំកូនស៊ុនទៅចាំអែបប្រែបទ្វារស្រុកដែលអ្នកសៀវនឹងចូលទៅនោះ ។

វេលាដែលអ្នកសៀវបានទទួលសំបុត្រហាន់ហ៊ុក មើលដឹងសេចក្ដីហើយក៏ចាត់ចែងសេនាទាហានលើកទៅស្រុកគីដីវ, អ្នកសៀវកាលចូលទៅដល់ទ្វារស្រុក គេងប៊ូនឹងកូនស៊ុន ដកគ្រឹបស្ទុះចេញទៅនឹងចាក់អ្នកសៀវ, ឆ័នលៀងនឹងប៊ុនទិវឃើញដូច្នោះ ក៏ស្ទុះដកគ្រឹបរត់ទៅការពារហើយកាប់គេងប៊ូនឹងកូនស៊ុនស្លាប់ ។ អ្នកសៀវលើកទាហានចូលទៅក្នុងស្រុក, ហាន់ហ៊ុកក៏ចេញមកទទួលហើយនាំទៅកាន់ទីសំណាក់រាជការ, អ្នកសៀវទទួលកាន់កាប់រក្សាស្រុកនោះពេញទី ហើយតាំងហាន់ហ៊ុកជាប៊ូបុងគុន ប្រែថា: "នាយទាហានឯក"; ឯបណ្ដាខុនរាជការក្រៅពីនោះអ្នកសៀវឲ្យដកហូតចេញទាំងអស់ ហើយតាំងកៀនហង១ចោស៊ីវ១ខៅស៊ីវ១ហង់គី ១ ដែលជាទាហានអ្នកសៀវនោះធ្វើជានាហ្មឺនក្នុងរាជការ ។ (មាន៩)

# ព្រះរាជពង្សាវតារប្រទេសកម្ពុជា

## ភាគទី ២

### សម័យនគរធំ

ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តមក)

## ព្រះបាទស្រីសាណាវរ្ម័នទី ២

ព.ស. ១៤៦៥ - ១៤៧១ គ.ស. ៩២២ - ៩២៨

កាលព្រះបាទហស៌វរ្ម័នទី ១ សោយទិវង្គតហើយ, ព្រះស្រីសាណ-វរ្ម័ន ជាអនុជាធិរាជ បានឡើងគ្រងរាជបល្ល័ង្កស្នងព្រះជេដ្ឋាធិរាជ មានព្រះបរមនាមថា "ព្រះបាទស្រីសាណវរ្ម័នទី ២" គង់នៅក្រុងស្រីយសោ-ធរបុរៈ ។ ទ្រង់មានព្រះអគ្គមហេសីព្រះនាមដូចម្តេច និង មានព្រះរាជឱរសព្រះរាជធីតាប៉ុន្មានទេ មិនប្រាកដក្នុងប្រវត្តិសាស្ត្រ ។

**ការផែនដី**: ក្នុងរជ្ជកាលនេះ មានរាជបុរោហិតឈ្មោះ កុមារស្វាមិ សឹងត្រូវជាក្មួយ សិវាស្រម ជាទីប្រឹក្សាការផែនដី និង ធ្វើពិធីផ្សេងៗថ្វាយ ។ ការផែនដី ក្នុងរជ្ជកាលនេះ បានចំរើនឬអាប់ឱនយ៉ាងណា មិនឃើញពោលដល់ ។ តែតាមសេចក្តីយល់ថា ព្រះមហាក្សត្រិយ៍អង្គនេះ មិនសូវមានព្រះតេជានុភាពដូចព្រះរាជបិតាទេ ដូច្នេះការផែនដីគង់ខ្សោយចុះបន្តិច ។

ស្ដេចស្ថិតនៅក្នុងរាជសម្បត្តិបាន ត្រឹម ៦ ឆ្នាំ ក៏សោយទិវង្គត, គេថ្វាយព្រះនាមព្រះបរមសពថា "បរមរុទ្រលោក" ។

## ព្រះបាទជយវរ្ម័នទី ៤

**ព.ស. ១៤៦៦ - ១៤៨៦ គ.ស. ៩២២ - ៩៤២**

កាលព្រះបាទឦសាណវរ្ម័នសោយទិវង្គតហើយ. រាជសម្បត្តិបានទៅព្រះជយវរ្ម័ន ។ ព្រះជយវរ្ម័នអង្គនេះ តំណព្រះវង្សមកអំពីព្រះជយវរ្ម័នទី ៣, មានដំណឹងក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នថា មានពួកព្រះរាជវង្សក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី ៣ ធ្វើការបះបោរដើម្បីដណ្ដើមរាជបល្ល័ង្ក តែព្រះបាទយសោវរ្ម័ននឹងព្រះរាជឱរសទ្រង់ការពារបានរហូតមក, លុះផុតរជ្ជកាលព្រះបាទឦសាណវរ្ម័នហើយ ជាឱកាសឲ្យព្រះរាជវង្សខាងព្រះបាទជយវរ្ម័នទី ៣ បានឡើងគ្រងបល្ល័ង្ករាជ្យ ទ្រង់ព្រះនាមថា "ព្រះបាទជយវរ្ម័នទី ៤" ។ ដំបូង ស្ដេចគង់នៅក្រុងស្រីយសោធរបុរៈ ទ្រង់មានព្រះអគ្គមហេសីព្រះនាមជយទេវី ជាព្រះរាជធីតារបស់ព្រះបាទឥន្ទ្រវរ្ម័នទី ១ ត្រូវជាកនិដ្ឋភគិនីនៃព្រះបាទយសោវរ្ម័នទី ១ មានព្រះរាជឱរស ១ អង្គព្រះនាម ហសិវរ្ម័ន ។

**ការផែនដី:** ក្នុងរជ្ជកាលនេះ មានរាជបុរោហិតចាស់ដែលធ្លាប់ធ្វើរាជការក្នុងរជ្ជកាលព្រះបាទឦសាណវរ្ម័ន គឺ កុមារស្វាមិ ជាទីប្រឹក្សាការផែនដី នឹង ធ្វើពិធីផ្សេងៗ ថ្វាយ ទ្រង់និយមនៅក្នុងលទ្ធិសៃវៈ ។

ក្រោយដែលទ្រង់បានទទួលព្រះរាជពិធីបរមរាជាភិសេកហើយ មិនយូរប៉ុន្មាន បានស្ដេចទៅសាងព្រះរាជធានីថ្មីមួយនៅជោគគរគ្យារ គឺនៅកោះកែក្នុងខេត្រព្រហ្មទេព ហើយស្ដេចទៅគង់នៅព្រះរាជធានីថ្មីនេះ បានទាំងនាំយករូបព្រះកម្រតេងជគតរាជទៅប្រតិស្ឋាននៅក្រុងថ្មីនោះផង ។ ព្រះហសិវរ្ម័នជារាជឱរសគង់នៅអនិន្ទិតបុរៈ ។

មានបញ្ហាថា ហេតុដូចម្ដេច បានជាព្រះបាទជយវរ្ម័នស្ដេចចេញចាកព្រះមហានគរស្រីយសោធរបុរៈ ដែលជានគរល្អបំផុត ទៅគង់នៅក្រុងតូចដែលទើបនឹងសាងថ្មីនោះវិញ? ។ រឿងនេះ អ្នកប្រវត្តិសាស្ត្របានទាក់ចិត្តដែរ តែមិនប្រទះហេតុផលល្មមនឹងដោះស្រាយបាន ក៏នៅជារឿងងងឹតដដែល ។ កិច្ចការក្រៅអំពីនេះក៏មិនមានអ្វីជាសំខាន់ដែលគួរនាំមកសំដែងក្នុងទីនេះ ។

ព្រះបាទជយវរ្ម័នទី ៤ ស្ដេចស្ថិតនៅក្នុងរាជសម្បត្តិបាន ២០ ឆ្នាំ ក៏សោយទិវង្គត, គេថ្វាយព្រះនាមព្រះបរមសពថា " ព្រះបាទបរមសិវបទ " ។

## ព្រះបាទហសិវរ្ម័នទី ២

**ព. ស. ១៤៨៥ - ១៤៨៧ គ. ស. ៩៤២ - ៩៤៨**

កាលព្រះបាទជយវរ្ម័នទី ៤ សោយទិវង្គតហើយ. ព្រះហសិវរ្ម័នជារាជឱរសបានឡើងសោយរាជ្យស្នងព្រះរាជបិតាតមក មានព្រះបរមនាមថា

“ព្រះបាទហរិវរ្ម័នទី ២” ។ ស្ដេចគង់នៅជោគគរគ្យារ, ទ្រង់មានព្រះអគ្គមហេសី ព្រះនាមដូចម្ដេច នឹងមានព្រះរាជឱរសព្រះរាជធីតាឬទេ គ្មានពោលដល់ ។

**ការផែនដី:** ក្នុងរជ្ជកាលនេះ មានរាជបុរោហិតឈ្មោះឦសាណមូរ្តិ ជាទីប្រឹក្សាការផែនដី នឹងធ្វើពិធីផ្សេងៗ ថ្វាយ ទ្រង់រាប់អានសាសនាព្រាហ្មណ៍ ។ ក្រោយរាជាភិសេកហើយ កើតសង្គ្រាមក្នុងព្រះនគរ ដោយព្រះរាជេន្ទ្រវរ្ម័ន ជាឱរស ព្រះនាងមហេន្ទ្រទេវី សឹងរួមព្រះអយ្យកោ ព្រះអយ្យិកាជាមួយគ្នាខាងព្រះមាតា បានលើកកំឡាំងទៅលុកព្រះអង្គ ដោយបំណងយកបល្ល័ង្ករាជ្យ ។ ព្រះបាទហរិវរ្ម័នទ្រង់លើកកងទ័ពចេញច្បាំងទប់ទល់ពេញទំហឹង ប៉ុន្តែទ្រង់ចាញ់ប្រៀបក្នុងផ្លូវកលយុទ្ធ ព្រះអង្គក៏សោយទិវង្គតក្នុងសមរភូមិ ។ ស្ដេចស្ថិតនៅក្នុងរាជសម្បត្តិបាន តែត្រឹម ២ ឆ្នាំ, គេថ្វាយព្រះនាមព្រះបរមសពថា “ព្រះបាទព្រហ្មលោក” ។

## ព្រះបាទរាជេន្ទ្រវរ្ម័នទី ២

**ព. ស. ១៤៨៧-១៥១១ គ. ស. ៩៤៤-៩៦៨**

ព្រះបាទរាជេន្ទ្រវរ្ម័ន កាលទ្រង់ធ្វើសឹកមានជ័យជំនះបានឡើងគង់លើរាជបល្ល័ង្កហើយ មានព្រះបរមនាមថា “ព្រះបាទរាជេន្ទ្រវរ្ម័នទី ២”

ស្ដេចគង់នៅមហានគរស្រីយសោធរបុរៈ, ទ្រង់មានព្រះអគ្គមហេសីព្រះនាម រាជេន្ទ្រទេវី ព្រះរាជធីតា ១ អង្គ ព្រះនាម ឥន្ទ្រលក្ស្មី ។

**ការផែនដី:** ក្នុងរជ្ជកាលនេះ មានរាជបុរោហិតឈ្មោះ អាត្មសិវៈ ត្រូវជាក្មួយឦសាណមូរ្តិ ជាទីប្រឹក្សាការផែនដី នឹង ធ្វើពិធីផ្សេង ៗ ថ្វាយ, ទ្រង់កាន់សាសនាព្រាហ្មណ៍ក្នុងលទ្ធិសៃវៈ, ទ្រង់មានសេនាបតីសំខាន់ ២ នាក់ គឺ ១ ងារជា រាជកុលមហាមន្ត្រី ជាអ្នកកាន់លទ្ធិសៃយ, ១ ទៀតឈ្មោះកវិន្ទ្រារិម័ទន៍ (?) ជាអ្នកកាន់ព្រះពុទ្ធសាសនា ។ សេនាបតីក្រោយនេះបានសាងព្រះពុទ្ធរូបទុកនៅប្រាសាទបាទជុំខ្លះ នៅក្រុងស្រីយសោធរៈបុរៈខ្លះ ។

សិលាចារឹកនៅប្រាសាទបក្សីចាំក្រុងថា ព្រះបាទរាជេន្ទ្រវរ័នទ្រង់លើកទ័ពទៅវាយនគរចម្ប៉ា មានជ័យជំនះ បាននគរចម្ប៉ាជាចំណុះកម្ពុជរដ្ឋជាថ្មីម្ដងទៀត (១) ។

ព្រះបាទរាជេន្ទ្រវរ័នទី ២ ស្ដេចស្ថិតនៅក្នុងរាជសម្បត្តិដរាបដល់ ព. ស. ១៥១១ ក៏សោយទិវង្គត, គេថ្វាយព្រះនាមព្រះបរមសពថា " ព្រះបាទសិវលោក " ព្រះអង្គមានព្រះកិត្តិយសជា រាជាធិរាជ ១ អង្គ ក្នុងប្រវត្តិសាស្ត្រ ។ (មានត)

---

• ក្នុងសិលាចារឹកនោះថាទ្រង់បានយកព្រះទេវរូបមាស ១ អង្គអំពីវិហារពោធិតាត ។

សាវតារវត្តវិហារធន្ទឹម

នៅឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម

ឧកញ៉ា កែវ - ហង់

ចាងហ្វាងរីវ៉ៃត្រុត នៅឃុំ - ស្រុក - ខេត្តនេះ រៀបរៀង

រង្វាន់លេខ ១

---

# ប្រវត្តិហេតុដើម

មានស្ដេចមួយអង្គទ្រង់ព្រះនាម ព្រះបាទឧទុម្ពរ អគ្គមហេសីមាននាមមិនប្រាកដ គង់នៅភូមិវិហារហ្លួង ស្រុកត្បូងឃ្មុំ ៗ ទ្រង់បានជីកស្រះ១ ធំ ទទឹងជាង ១០០ម៉ែត្រ បណ្ដោយប្រហែល ៤ ឬ ៥ រយម៉ែត្រនៅខាងកើតវត្តវិហារធន្ទឹមសព្វថ្ងៃនេះ ៗ ស្ដេចនេះមានបុត្រីមួយអង្គតែព្រះនាមមិនប្រាកដ ៗ មានសត្វក្រពើខាំបុត្រីស្ដេចនេះពាំនាំយកមកបោកនៅវាលខាងជើងវត្តវិហារធន្ទឹម គេហៅជាប់មកដល់សព្វថ្ងៃថាវាលត្បូងក្រពើ, កាលវាលេបបុត្រីស្ដេចនេះហើយក៏គេបរត់បាត់ទៅ, ស្ដេចឲ្យពលរេហ៍តាមរកក្រពើនោះ តែតាមរកមិនឃើញ (តាមស្មានកាលពីដើមប្រហែលទន្លេនេះជាសមុទ្រពេញទាំងអស់), ស្ដេចឲ្យវាស់ថ្នល់ដែលលើកជាប់ពីក្នុងពានជាំងទៅបន្ទាយព្រៃនគរ គឺបន្ទាយស្ដេច កន ក្នុងឃុំជួនតីសព្វថ្ងៃ ៗ ពលបានទំលាយថ្នល់បង្ហូតទឹកឲ្យរីងធ្វើផ្លោះបិទមិនឲ្យក្រពើ

ចេញរួច, ដល់ហូរវិញទឹកគោកហើយ ក្រពើក្អួតខ្មោចបុត្រីស្ដេចអង្គនោះ ដែលហើមហើយនៅក្នុងឃុំដីគរ; ត្រង់ទីនោះជាប់ហៅមកថា គោកហើម ៗ ទឹកក្នុងស្រះធំដែលស្ដេចជីកខាងលើគឺគោករវិញ ស្រះនោះគេហៅថា ទន្លេសួត រហូតសព្វថ្ងៃ ៗ ឯសត្វក្រពើរត់មកចូលរូងខាងកើតវត្តវិហារខ្ពស់ ក្នុងឃុំសួង គេហៅជាប់មកថា ក្បាលរូង; សព្វថ្ងៃមានទឹកហូរចេញជាប្រក្រតី ខួបប្រាំងវស្សាមិនដែលដាច់ ៗ ស្ដេចយកសពបុត្រីទៅធ្វើចេតិយដាក់នៅជិតស្រះធំខាងលើ ហើយទ្រង់ឲ្យជីកស្រះតូច ១ ទៀត នៅមុខចេតិយរៀបពីថ្មបាយក្រៀម, ចេតិយនោះមានដើមដៃដុះស្រោបបាក់បែកអស់ គេហៅថា ប្រាសាទដៃរយោង រហូតមកដល់សព្វថ្ងៃ, ប្រាសាទនេះ នៅជាខាងកើតវិហារទន្ទឹម ប្រហែល ៣ ឬ ៤ រយម៉ែត្រ ៗ

## និយាយពីវត្តវិហារទន្ទឹម

ព្រះបាទទុទុម្ពរ កាលក្រោយសត្វក្រពើខាំបុត្រី ទ្រង់បានយាងមកកសាងវត្តវិហារទន្ទឹមនេះ, ឯអគ្គមហេសីសាងវិហារ ១ ជាខាងជើងទន្ទឹមគ្នានឹងវិហារដែលស្ដេចប្ដីសាង ធ្វើពីគ្រឿងឈើប្រក់ស្បូវ បានជាហៅថា វិហារទន្ទឹម ដល់មកសព្វថ្ងៃនេះ ៗ ស្ដេចបានជីកស្រះ ១ ខាងមុខវត្តយកដីមកលើកខឿនវិហារទាំងពីរនោះ បានទាំងជីកស្រះពីរតូចៗ ចំមុខវិហារខាងជើង ១ ខាងត្បូង ១ រៀបពីថ្មបាយក្រៀមមានជណ្ដើរ ៤ ចុះទៅក្នុងស្រះ; តែស្រះ ១ ខាងត្បូងរលុបហើយ នៅតែខាងជើង

សព្វថ្ងៃនេះបាក់បែកស្រុតខូចអស់ជាច្រើន ។ មានថ្មចំឡាក់របៀបខ្លោងទ្វារនៅសល់ខ្លះសព្វថ្ងៃនេះ ឮថាមានចារឹកអក្សរផង តែបាត់បង់ទៅយូរហើយ ។ តាមដំណឹងថា វត្តវិហារទន្ទឹមនេះ ព្រះបាទធម្មត្រៃទ្រង់សាងមុនអង្គរព្រះជ័យកំពង់ចាម ពីពុទ្ធសករាជប៉ុន្មានមិនប្រាកដ ។

កាលពី គ.ស. ១៩១២ ខ្ញុំបាទចេញមកធ្វើសុភាខែត្រត្បូងឃ្មុំនេះ, កាលណោះមានឈ្មោះ ស អាយុ ៦២ ឆ្នាំ, ឈ្មោះមន្ត្រីអញ្ចិត សំ អាយុ ៥៩ ឆ្នាំ នៅឃុំវិហារហ្លួង, ឈ្មោះយោក្បត្រ ប៉ុល អាយុ ៦០ ឆ្នាំ, ឈ្មោះអ្នក អាយុមិនចាំ តែចាស់ណាស់ហើយ នៅឃុំសួង; អ្នកទាំងអំបាលនេះបាននិយាយដំណាលរឿងព្រះបាទធម្មត្រៃសាងវត្តវិហារទន្ទឹម ដូចខាងលើនេះ តែអ្នកអំបាលណោះ ឥឡូវនេះអនិច្ចកម្មអស់ទៅហើយ ។ ពីមុនមានឈ្មោះ ឃុំវិហារទន្ទឹម ជាប់មក តែដល់ គ.ស. ១៩២៦ រាជការរួមឃុំវិហារទន្ទឹមបញ្ចូលទៅក្នុងឃុំសួង ។

## ១ – និយាយពីរបៀបកសាងវត្ត

កាលព្រះបាទធម្មត្រៃកសាងវត្តវិហារទន្ទឹមនេះ ធ្វើដូចក្បួនខាងក្រោមនេះដែរ ឬដូចម្ដេចខ្ញុំបាទមិនដឹង ។

មានក្បួនមួយនិយាយពីរបៀបកសាងវត្ត កសាងនិវេសន៍វាំងស្ដេចនឹងភូមិ ក្បួននោះឈ្មោះថា ក្បួនត្រៃភូមិ ។

អ្នកស្រុកភូមិមានគ្នាច្រើនល្មមកសាងវត្តមួយបាន ដើម្បីកុំឲ្យពិបាកដើរទៅធ្វើបុណ្យទានឯវត្តដទៃឆ្ងាយ ក៏នាំគ្នាចូលទៅសុំច្បាប់ដល់សម្ដេចព្រះមហាសង្ឃរាជៗ នាំយកសេចក្ដីក្រាបទូលព្រះមហាក្សត្រិយ៍ ។ លុះបានអនុញ្ញាតហើយ អ្នកស្រុកតែងរកអាចារ្យហោរាដែលចេះក្បួនច្បាប់ទៅមើលទីកន្លែងដី ។ តាមក្បួន ឲ្យរើសរកដីរបៀបខ្នងជើងឆ្វេងមនុស្សដែលឈរបែរមុខទៅទិសខាងកើត សម្រាប់ធ្វើវត្ត-វាំង-ភូមិ ។ អាចារ្យវាស់ទទឹង-បណ្ដោយដីជាគំរួយបានហើយផ្អាកទុក ។ អាចារ្យមើលឫក្សខែថ្ងៃនឹងវាស់បែងក្រឡានាទីដីនោះ រួចឲ្យធ្វើរាន ៣ ថ្នាក់ មានបាយសីស្លាធម៌ ទឹកអប់ សំពត់សក្រាលរាន មានឆ័ត្របាំងរាន មានរៀបព្រះពិស្ណុការ ជម ៤ សំពត់ស ១ អាវ ទៀនធូប ៥ ផ្លែឈើ ៤ ប្រាក់ ១ រៀល ស្រា ១ ដបផង ។ អាចារ្យឲ្យនិមន្តលោកចៅអធិការវត្តដែលនៅជិតឲ្យទៅឈរនៅក្នុងទីដីនោះ ហើយទាញខ្សែវាស់ដីនោះ ពីព្រិខាងកើតទៅព្រិខាងលិច ពីត្បូងទៅឯជើង ខ្សែនោះយកមកបត់ជាពីរ, រួចទាញខ្សែបត់ពីព្រិខាងកើតទៅឯលិច ពីត្បូងទៅឯជើង ពាក់កណ្ដាលដី ចុងខ្សែបត់ជួបគ្នាត្រង់ណា អាចារ្យឲ្យបោះគោលត្រង់ណោះៗ ហៅថា ផ្ចិតវត្ត ។ ឯលោកចៅអធិការដែលនិមន្តទៅឈរ វេលាអាចារ្យវាស់ដីនោះ ហៅថាចៅទៃ, អាចារ្យឲ្យរៀប បន្ថែម ចំអាប កន្ទេល ខ្នើយ ប្រអប់ស្លា សំពត់ដាក់លើឆ្វេង-ស្ដាំ ទឹកសំបួរ ១ ផ្តិល, ធ្វើពែ ១ មានកន្ទោងបាយស-

ក្រហម យកទៅដាក់រៀបត្រង់គោលផ្ចិតវត្ត ហើយសូត្រអញ្ជើញទេវតាគ្រប់ចក្រវាឡនឹងព្រះភូមិ - នាងគង្ហីងព្រះធរណី, សូត្ររួចហើយសែនពែសុំទឹកដីពីនាងគង្ហីងព្រះធរណី នឹង សុំពីព្រះភូមិ សុំកសាងវត្តថ្មីនេះ សែនហើយផ្កាប់ពែ ៗ អាចារ្យវាស់បែងក្រឡាទីដីនេះ ជា ២៥ ក្រឡាផ្ទាំង មានឈ្មោះគ្រប់ក្រឡាផ្ទាំង (តែចាំមិនអស់) យកតែក្រឡាផ្ទាំងណាខ្លះដែលត្រូវការប្រើ, ត្រង់គោលផ្ចិតវត្ត សង់សាលាកុដិឬធ្វើអ្វីមិនបានទេ ៗ ក្រឡាផ្ទាំងព្រះមហោសថ សង់ព្រះវិហារ, ក្រឡាផ្ទាំងជោគសេដ្ឋីឬមហាសេដ្ឋី សង់កុដិចៅអធិការ, ក្រឡាផ្ទាំងព្រះពិធូរ សង់សាលាធ្វើបុណ្យទាន ព្រោះព្រះពិធូរចេះសំដែងធម៌, ផ្ទាំងសង់សាលាធាន់មិនចាំជាហៅថាផ្ទាំងអ្វី ៗ (គាត់ខ្ញុំចាំមិនអស់) អាចារ្យយកនាមភូមិនឹងនាមវត្តមកផ្សំគ្នា (តែមិនចាំតួអក្សរណាផ្សំនឹងតួណាថាដូចម្តេច) ផ្សំនាមបានហើយអាចារ្យរាប់មូលនៅត្រង់ទិសណា រាប់មូលជាដំបូងនៅទិសនោះជាមូល, ឧស្សាហ៍, មន្ត្រី, កាឡកណ្ណី, បរិវារ, អាយុ, តេជះ, សិរី ៗ ឯកាឡកណ្ណី សង់បង្គន់, បរិវារ សង់កុដិភិក្ខុជាបរិស័ទ្យ, មន្ត្រី សង់ផ្ទះអ្នកតា ហៅថាចៅមឿង (ចាំមិនសព្វទេឲ្យមើលក្បួនត្រាភូមិ) ៗ ទ្វារវត្តមាន ៤ គឺទ្វារឯកើត - លិច - ត្បូង - ជើង ៗ វាំងស្តេចដូចគ្នានឹងវត្ត ហៅថាទ្វារត្រឡែងកែង ៗ ជីកស្រះខាងកើតឈៀងត្បូងសានវត្ត ៗ ខាងខែត្រតាកែវ ច្រើនជីកស្រះជុំវិញវិហារឬជីកក្រៅរបងវត្ត ហៅថាអង្គ ដូចវត្តខ្ទះ

ឈ្មោះវត្តអន្លង់ណ, អន្លង់សឹង, អន្លង់រំពាត់, អន្លង់ធុក, អន្លង់តាសោម; វត្តណា គ្មានដីកស្រះជុំវិញ គេមិនហៅអន្លង់ទេ ។ (ក្បួននេះឮចាស់ៗថា ជារបស់លោកវង្សាសារពេជ្រមុន ហោក (ដូង) ជាហោរាព្រះករុណាសុវណ្ណកោដ្ឋ, ចាស់ៗដែលសរសេរក្បួននេះស្លាប់អស់) ។ មុនដំបូងបាននាទីដី អាចារ្យបែងក្រឡាដីហើយ ត្រូវធ្វើកុដិលោកទៅអធិការមុន ហើយធ្វើរោងឧបោសថ រួចសង់សាលាជាបណ្ដោះអាសន្នតមក ។

## ២— និយាយអំពីលើកវិហារ

ពេលល្ងាច អាចារ្យឱ្យរៀបពលីការត្រង់ផ្ចិតវត្ត មានកន្ទេលខ្នើយ សំពត់សក្រាល មានបង្អែមចំអាប សំពត់ថ្កុលធ្វើង-ស្ពាំ មានប្រអប់ស្លា ទឹកសំបួរ មានអម្បោះក្អុក ពៃព្រះភូមិ មានស្លាធម៌ ៨ ទិស ដាក់ជុំវិញទីវិហារ មានពានទេវតា ១ ខាងកើត មានប្រដាប់បាយសី ទឹកអប់ ស្លាបារី កន្ទេល ខ្នើយ ។ អាចារ្យធំសូត្រអញ្ជើញទេវតាព្រះភូមិសព្វគ្រប់ហើយ សែនពៃនិយាយថា "ឱ្យតេជះព្រះភូមិព្រះធរណីព្រះស្រុក, ថ្ងៃនេះថ្ងៃជាពេលាល្អ យើងបានរៀបពលីការថ្វាយអស់លោកជាម្ចាស់ទឹកដី ជាម្ចាស់ភូមិហើយ, ដ្បិតយើងនឹងរៀបលើកវិហារថ្វាយសង្ឃ ថ្ងៃស្អែកនេះជាថ្ងៃនក្ខត្តឫក្សជោគជ័យសួស្ដី សូមឱ្យអស់លោកជួយទំនុកបំរុងឱ្យបានសេចក្ដីសុខ កុំឱ្យមានរោគាភិតភ័យឡើយ បើមានសេចក្ដីអន្ដរាយមកពីមុខឱ្យរំលង មកពីក្រោយឱ្យរលាយ" ថាដូច្នេះបីដងហើយចាប់បាយសម្

ដាក់ប្រមូលក្នុងពានមួយ រួចពាក់ត្រង់ផ្ចិតវត្តនោះ ហើយលើកប្រដាប់ទាំងនោះទៅក្រងពាលីនៅទិសសសរណាដែលត្រូវលើកមុន ។ អាចារ្យក្រងពាលីហើយបាចបាយដាក់ក្នុងពែ រួចហើយសែនរបៀបដូចមុន គ្រាន់តែផ្លាស់ឈ្មោះស្តេចក្រងពាលី រួចហើយផ្កាប់ពែនៅទិសសសរនោះ រួចយកអំបោះក្នុកនឹងអំបោះខ្សែដែបង់សសរនោះប្រស់ទឹកសម្បូរ ហើយរៀបចំរើនព្រះបរិត្តក្នុងលានទីវិហារ (និយាយខ្លះ) មានពានទេវតាធំ ១ មានប៉ាំងរាជវតិ អណ្តាប់មានព្រម, មានអាចារ្យរង ២ នាក់ចូលគាន់ត្រណមតាំងពីពេលយប់សូត្រចំរើនព្រះបរិត្ត, ព្រឹកឡើង អាចារ្យធំបាត់ឲ្យលើកសសរបង់អំបោះក្នុកតាមពេលអាចារ្យបង្គាប់, មានបង់ខ្ញុំ ១ ប៉ាំងក្បាលសសរនោះ ៗ តាមរបៀបពីដើម, លើកវិហារត្រូវចូលក្រាបទូលសម្តេចព្រះមហាសង្ឃរាជ សុំឲ្យយាងមកជាអធិបតីលើកវិហារនោះ, ត្រូវបៅអធិការឬអាចារ្យវត្តមានពួអំបោះ ១ គូប ចំសំពត់ជាតី សំពប់ថ្វាយលើកសសរ (សម្តេចព្រះមហាសង្ឃរាជផ្លាល់ព្រះហស្តទាញធ្វើជាមង្គល) ។ ដំណាតមក មុខងាររនេះ ត្រូវបៅហ្វាយស្រុកឬកំមេឃុំឬលោកអ្នកមានយសសក្តិ មកជាអធិបតី ។

## ៣ – និយាយអំពីរបនាបោះជាងវិហារ

ក្បាច់បោះជាងវិហារ ខ្ញុំមិនដែលឮថាមានក្បួនច្បាប់ឲ្យធ្វើបែបនេះបែបនោះទេ ។ យល់ឃើញថាក្បាច់បោះជាង គ្រាន់តែជាសញ្ញាឲ្យ

ចំឡែកក្អែក ព្រោះធ្វើលាតមិនល្អមើលប៉ុណ្ណោះ ។ អស់លោក-អ្នកកសាងវិហារមានគំនិតគិតថា ក្នុងលោកមានអ្វីដែលមានឥទ្ធិរិទ្ធិ ក៏យករូបនោះមករចនាដាក់នៅហោជាង ឲ្យប្លែកហើយល្អមើលផង ។

ខ្លះធ្វើដំរីក្បាលបីដែលឈ្មោះឰរាវ័ណ្ណ, ខ្លះធ្វើរូបព្រះនារាយណ៍គង់លើក្បាលដំរីនោះ, ខ្លះធ្វើរូបគ្រុឌជើងចាប់នាគម្ខាង ១ ដៃកាន់កន្ទុយនាគ ធ្វើរូបព្រះនារាយណ៍ឈរជាន់លើស្មាគ្រុឌ, ខ្លះធ្វើរាហ៊ូចាប់ព្រះច័ន្ទ ឬព្រះអាទិត្យ ធ្វើរូបព្រះនារាយណ៍ឈរលើស្មារាហូ ។ ក្រៅពីនេះ ជាងគូរឆ្លាក់ក្បីភ្ញើង ក្បីទេស ក្បីវល្លិ៍នៅហោជាងអមរូបទាំងនោះ ដូចជាហោជាងប្រាសាទព្រះមហាក្សត្រ ធ្វើព្រះសង្ហាជាសញ្ញា ។ វត្តណាចៅអធិការមានសមណសក្តិជាពជាគណៈបានសាងវិហារវត្តនោះ ជាងឆ្លាក់ក្បាច់ហោជាងធ្វើជាផ្ចិតស្រួច ។ វត្តណាលោកចៅអធិការបានហាត់សិក្សាគម្ពីរបាលី ជាងធ្វើក្បាច់ហោជាងជាគម្ពីរពានទ្រជាសញ្ញា ។ (មាន៩ត)

---

**ផលកាន់ទំនៀមទម្លាប់**

ទំនៀមល្អកាន់កើតសួស្តី
ទម្លាប់ពិសីកាន់កើតសុខា
ទំនៀមខុសកាន់ថោកអាត្មា
ទម្លាប់លាមកាកាន់កើតទុក្ខភ័យ ។

យូរ-អ៊ុន

ពន្លឺអាស៊ីទ្វីប

# លោក វ៉ាយ-ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

(តមក)

ព្រលឹងរបស់បុគ្គលនោះចាកចេញពីរូបកាយ ដើម្បីជាកិត្តិយសដល់ការទទួលទុក្ខលំបាក នឹង ដើម្បីប្រាថ្នាទៅកាន់ស្ថានសុខ ចំពោះបុគ្គលណាដែលបានរងទុក្ខទាល់តែទេវតាអៀនខ្មាស តាមសេចក្តីដែលមានសំដែងក្នុងគម្ពីរជាហេតុធ្វើមនុស្សឲ្យមានសមភាពនឹងទេវតា ធ្វើឲ្យមានពលភាពឈ្នះនូវសេចក្តីទុក្ខក្នុងស្ថាននរកបាន ។

ព្រះសិទ្ធត្ថទ្រង់ទតមើលឃើញបុគ្គលម្នាក់ដែលជាគ្រូអាចារ្យ នៃពួកដែលរងទុក្ខលំបាកនោះ ហើយមានព្រះឧង្ការថា "ឱអ្នក! ខ្លួនអ្នកបានរងទុក្ខលំបាកជាខ្លាំង តាំងពីយូរខែណាស់មកហើយ, ខ្ញុំនៅនឹងភ្នំនេះ ខ្ញុំខំស្វះស្វែងរកធម៌ពិតធម៌មែន ហើយខ្ញុំមកឃើញអ្នកនឹងបុគ្គលឯទៀតធ្វើបាបខ្លួនឯង គួរឲ្យសង្វេគពន់ពេក, ក្រែងអ្នកយល់ឃើញថាទុក្ខក្នុងជីវលោកមានស្រាប់ហើយ ហេតុម្តេចក៏អ្នកធ្វើទុក្ខនោះឲ្យកាន់តែទ្វេឡើងទៀត?" ។

គ្រូអាចារ្យនោះក្រាបទូលព្រះសិទ្ធត្ថថា "មានចារិកទុកក្នុងគម្ពីរថា: បើបុគ្គលណាបានធ្វើបាបខ្លួនឯង បុគ្គលនោះរមែងទទួលនូវសេចក្តី

ឈើចាប់ជាច្រើនយ៉ាង ទាល់តែនៅត្រឹមខ្យល់អស្សាសៈបស្សាសៈប៉ុណ្ណោះ ហើយមានចិត្តសង្ឃឹមថា : នឹងទទួលមរណភាពដោយសោមនស្សបែបនេះ; ដោយអំណាចទទួលនូវទុក្ខលំបាកជាខ្លាំង បុគ្គលនោះ ក៏អាចលាងបាបអកុសលចេញពីក្នុងសន្តាន ហើយព្រលឹងដែលបរិសុទ្ធស្អាតបាកចេញពីសេចក្តីទុក្ខក្នុងលោកនេះឡើងទៅកាន់ស្ថានដ៏ឧត្តម ដែលប្រកបដោយសេចក្តីសុខជាអស្ចារ្យ" ។

ព្រះសិទ្ធត្ថទ្រង់តបវិញថា : "ពពកដែលអណ្តែតត្រសែតលើនភាល័យ ដែលត្រដាងដូចជាសំពត់កោសេយ្យពស្ត្រ មានពណ៌ដូចមាសគេរុំជុំវិញតេនបល្ល័ង្កនៃសម្តេចព្រះឥន្ទ្រាធិរាជ, ពពកទាំងនោះបាកចេញហុយពីសមុទ្រឡើងទៅលើអាកាស ហើយត្រវិលធ្លាក់មកជាភ្លៀង, ទឹកភ្លៀងនោះហូរធ្លាក់ទៅតាមផ្លូវ ថ្មក ស្ទឹង រួចហូរចុះទៅដល់ទន្លេហើយហូរធ្លាក់បាក់ទៅកាន់សមុទ្រជាទីដែលទឹកនោះធ្លាប់តាំងនៅពីមុនវិញ; អ្នកដឹងឬទេ? សភាពលោកមានការប្រែប្រួលជាធម្មតា; ក្រែងអ្នកមកទទួលទុក្ខលំបាកបែបនេះដើម្បីនឹងស្វែងរកសុខឬ? ដោយហេតុថា : របស់អ្វីដែលឡើងទៅកាន់ទីខ្ពស់តែងធ្លាក់មកទាបវិញ, វត្ថុអ្វីដែលគេទិញបានគេត្រវិចកចាយទៅវិញ; ចុះបើអ្នកយកលោហិតទៅទិញមហាមេឃនៅផ្សារ គឺទុក្ខលំបាកក្នុងស្ថាននរកហើយ តើអ្នកនឹងចៀសពីនរកម្តេចបាន, អ្នកនឹងត្រឡប់សោយទុក្ខវិញមិនខាន" ។

អាចារ្យនោះតបថា "ទុក្ខនោះតែងតែអន្ទោលទៅមក តែងកើតឡើងជាថ្មី មិនចេះផុតមិនចេះហើយ យើងមិនអាចទុកចិត្តនូវវត្តុក្នុងលោកបានទេ ដោយហេតុថាក្នុងវេលាថ្ងៃនិងយប់ មានសេចក្ដីស្លាប់ រួចសេចក្ដីកន្សល់មកដល់ យើងមានចិត្តស្អប់ខ្ពើមសាច់អាក្រក់ដែលរាំងរាមិនឲ្យអាត្មានចាកចេញពីរូបទៅបាន; ព្រោះហេតុដូច្នេះ ដើម្បីនឹងស្វែងរកសេចក្ដីសុខចំពោះអាត្មាននេះ យើងត្រូវធ្វើបាបខ្លួនយើង ចំពោះមុខពពួកទេវតាទាំងឡាយ ដើម្បីនឹងប្ដូរយកសេចក្ដីសុខទីបំផុតឯនោះ" ។

ព្រះសិទ្ធត្ថតបទៅវិញថា "តាមស្មានថា: សេចក្ដីសប្បាយមានកំណត់មួយលានឆ្នាំ, សេចក្ដីសប្បាយនោះដល់យូរទៅគង់ស្រពោនរុះរោយមិនខាន, បើមិនដូច្នោះទេ តើមានសត្វណានៅខាងក្រោម ខាងលើ ឬជិតទីនេះ ឬក៏ផ្សេងពីទីនេះមិនចេះប្រែប្រួលដែរ? សូមអ្នកប្រាប់ខ្ញុំ; តើទេវតារបស់អ្នកមានជីវិតរស់នៅស្ថិតស្ថេរជានិច្ចឬ? ។

អាចារ្យនោះក៏តបទៅព្រះអង្គវិញថា "បើតាមសេចក្ដីយល់របស់ពួកយោគី មានតែព្រះព្រហ្មមួយដែលលោកនៅជានិច្ច ចំណែកខាងទេវតាគ្រាន់តែរស់នៅមួយពេល" ។

ព្រះសិទ្ធត្ថមហាបុរសមានព្រះបន្ទូលថា "ចុះអ្នកចង់តាំងខ្លួនជាពួកសន្តិឬ? ខ្ញុំស្មានថា ចិត្តអ្នកប្រាថ្នាសន្តិភាពនិងសេចក្ដីក្លាហាន, បើដូច្នេះត្រូវអ្នកបោះបង់ចោលការកំណាចសាហាវ ដែលនាំឲ្យអ្នកប្រកបដោយ

សោកបរិទេវទុក្ខ ដែលនាំអ្នកទៅកាន់បំណងមិនប្រាកដហើយមិនស្ថិតស្ថេរនេះចេញ; គួរបើដៃរ ដោយហេតុតែសេចក្ដីស្នេហាចំពោះអាត្មនរបស់អ្នកៗ ទៅជាស្អប់សាច់ អ្នកធ្វើទុក្ខលំបាកដល់វា ទាល់តែរូបកាយនោះស្គមប្រដក់មិនអាចរក្សានូវចិត្តៗ នោះចំរកទីដែកពឹងពួនវង្វេងផ្លូវមុនពេលយប់ ដូចជាអស្សតរស្ងួតតែគេប្រើហួសកំឡាំង; ឱសិ ! ចុះអ្នកក្រែងចង់ធ្វើឲ្យវិនាសអតីតជាតិដែលប្រកបដោយទុក្ខ តើអ្នកបានសំឡឹងរកផ្លូវវិសេសតាមចន្លោះបង្អួចដែលមានរស្មីចាំងចូលមក អាចឲ្យមើលទៅខាងក្រៅបាន ដើម្បីនឹងឲ្យដឹងថាជាពេលព្រឹកព្រហាមហើយឬ? តើផ្លូវវិសេសថ្ងៃថ្លានោះនៅឯណា ?" ។

ក្នុងពេលនោះ ពួកយោគីទាំងអស់ស្រែកថា "យើងបានជ្រើសរើសយកផ្លូវនេះហើយ, យើងនឹងធ្វើដំណើរទៅតាមផ្លូវនេះឲ្យផុតដើមចុង; ឱព្រះរាជបុត្រ ! បើទុកណាជាតាមផ្លូវនេះមានចុះចេញសុទ្ធតែភ្លើងក៏ដោយ យើងគង់មិនចាកចេញពីផ្លូវនេះទេ; យើងសង្ឃឹមតែនឹងទៅកាន់សេចក្ដីស្លាប់ប៉ុណ្ណោះ, យើងសូមសួរព្រះអង្គៈ តើព្រះអង្គជ្រាបនូវផ្លូវដែលវិសេសជាងនេះទៅទៀតឬ? បើមិនជ្រាបទេ, សូមស្ដេចយាងចេញពីទីនេះចុះ" ។

ព្រះសិទ្ធត្ថបានធ្វើដំណើរតាមផ្លូវតទៅទៀត មានព្រះទ័យព្រួយជាខ្លាំង ដោយព្រះអង្គយល់ថា "មនុស្សទាំងអស់ខ្លាចសេចក្ដីស្លាប់, ហើយមានសេចក្ដីតក់ស្លុត ភ័យ ខ្លាច មានបំណងចង់ឲ្យជីវិតរស់នៅ

មានចិត្តស្អប់ជីវិតិន្ទ្រិយនោះ ធ្វើទុក្ខលំបាកជីវិតជាខ្លាំង ប្រហែលជាចង់ឲ្យទេវតាសោមនស្សសប្បាយ, ប៉ុន្តែទេវតាមិនព្រមឲ្យសេចក្តីសុខមកមនុស្សទាំងនោះទេ, ឬប្រហែលចង់ធ្វើខ្លួនឲ្យធ្លាក់ទៅកាន់ស្ថាននរករួចក៏បង្កបំពោះខ្លួនឲ្យទៅសោយទុក្ខក្នុងស្ថាននរកឯទៀត, ឬក៏ប្រហែលដោយមានពេលវង្វេងឆ្កួត មានសេចក្តីសង្ឃឹមថា: អាត្ម័ន ចេញពីរូបកាយដែលមានរបួសទុក្ខលំបាកងាយជាជាងរូបកាយដែលស្អាតល្អយ៉ាងនេះទេដឹង”ៗ ព្រះសិទ្ធត្ថក៏ពោលថា “ឱ បុប្ផាក្នុងច្បារឱទ្យានអើយ! អ្នកបែរមុខទៅកាន់ព្រះអាទិត្យមានសេចក្តីរីករាយសប្បាយនឹងពន្លឺរស្មី បានបញ្ចេញគន្ធ-ពិដោរក្លិនក្រអូបឈ្ងុយឈ្ងប់ ហើយមានរូបឆោមលោមពណ៌ ដូចសុ-វណ្ណពណ៌សដូចប្រាក់ក្រហមឆ្អៅ ដែលអ្នកបានមកពីអានុភាពនៃពន្លឺរស្មីនោះ; មិនមានបុប្ផាណាមួយអាចលះបង់ជីវិត រស់នៅបរិសុទ្ធស្អាត, មិនមានបុប្ផាណាមួយអាចលះបង់នូវសេចក្តីស្អាតស្រស់បំព្រងរបស់ខ្លួនចេញឡើយ, ឱដើមត្នោតអើយ! អ្នកមានដើមដងដុះនៅទីនេះ មានបំណងចង់ទំលុះមេឃ ហើយនឹងក្រេបផឹកនូវព្រះពាយ ដែលបក់មកពីភ្នំហិមាល័យនិងមហាសាគរ មានពណ៌ខៀវផ្ទៃមេឃ តើអ្នកបានដឹងនូវការស្ងាត់កំបាំងអ្វីដែលធ្វើឲ្យអ្នកដុះរស់នៅជាសុខសប្បាយ តាំងពីពន្លកចេញពីគ្រាប់ដំបូងរហូតដល់មកពេលដែលមានផ្លែហើយ កាលណាខ្យល់បក់ត្រូវស្លឹក ក៏មានសព្ទសូរដូចតន្ត្រីអ្វីពីរោះម្ល៉េះ?

(មានត)

លោក មុញ - ឆាគ្រី រៀបរៀង

(តមក)

## គ្រិស្តសាសនា

## ២ – លទ្ធិប្រូតេស្តង់

សព្ទនេះបានសេចក្តីថា "លទ្ធិទទឹងតាស់" ឬថា "លទ្ធិកែទម្រង់" (Réforme) ជាឈ្មោះនិកាយដែលបែកចេញមកអំពីនិកាយកាតូលិក ក្នុងរវាង ព. ស. ២០៦០, គ. ស. ១៥១៧ ដោយសារពាហិរបព្វជិតជាតិអល្លឺម៉ង់មួយរូបឈ្មោះលូថេរ[១] (Luther) ជាអាចារ្យសាលាវិទ្យាល័យវិត្តិតេម្បែរ ប្រទេសអល្លឺម៉ាញ ។

ហេតុដែលនាំឲ្យបែកចេញជានិកាយថ្មីនេះឡើង មកអំពីទោសនៃការប្រព្រឹត្តិជ្រោកជ្រាកខុសចាកគម្ពីរប៊ីប្ល (Bible) នៃគណៈសង្ឃអលជ្ជីមានសម្តេចព្រះសង្ឃរាជក្រុងរោមជាដើម ។ តាមសេចក្តីដំណាលថា: សង្ឃរាជនោះមានការចិញ្ចឹមជីវិតដូចគ្រហស្ថ ហើយខ្លួនគាប់ចិត្តយ៉ាងណា ក៏ប្រជុំគណៈសង្ឃមកបញ្ញត្តសិក្ខាបទយ៉ាងនោះ ទាំងបញ្ញត្តិថ្មីដែលសង្ឃរាជឬគណៈសង្ឃបញ្ញត្តទាំងអម្បាលម៉ាន, គ្រិស្តបរិសទ្យធ្លាប់ចុះចិត្ត

---

១ មាទ្ទិន លូថេរ (Martin-Luther) :កើតនៅស្រុកអីស្លេបេន គ. ស. ១៤៨៣ បែកចាកពួករោម៉ាំង - កាតូលិក (នៅវេលាប្រកាសចុះទោស) គ. ស. ១៥១៧ ក្នុងជំនាន់សង្ឃរាជឡេអុង ទី ១០ ក្នុងរាជ្យព្រះបាទសារឡឺម៉ាំង ដែលទ្រង់ឲ្យកាត់ទោស បញ្ជាឲ្យនិរទេសបណ្តេញចាកសាសន៍នៅសាលាវិនិច្ឆ័យ ក្រុងវ៉ម គ. ស. ១៥២១ ។

ជឿស៊ប់ថាជាបញ្ញត្តិរបស់ព្រះម្ចាស់សួគ៌ គឺព្រះជាម្ចាស់សួគ៌ឲ្យបញ្ញត្តនោះហើយជាឱកាសឲ្យសង្ឃរាជឬគណៈសង្ឃបញ្ញត្តតាមសេចក្ដីយល់ឃើញថាស្រួល ។

លទ្ធិកាតូលិក យើងធ្លាប់ដឹងមកហើយថា មានពិធីលាងបាប ។ ឯលទ្ធិនេះ បើបុគ្គលមានទោសល្មម ក៏អាចរួចទោសបានដោយពិធីសូត្រមន្តអង្វរករសូមខមាទោសនឹងព្រះជាម្ចាស់; បើបុគ្គលមានទោសធ្ងន់ត្រូវតែនៅបរិវាសកម្ម ឬដើរធុតង្គរុក្ខមូល ទៅនមស្សការកន្លែងព្រះហឫហ្សូប្រសូត ជាកិច្ចទណ្ឌកម្ម ទើបរួចទោសបាន ។

ថ្ងៃមួយជាហេតុនាំឲ្យផ្ទុះចេញជាលទ្ធិនេះឡើង, សម្ដេចព្រះសង្ឃរាជក្រុងរ៉ោមចង់សាងវិហារវត្ត (Saint-Pierre) ឲ្យល្អធេតជាប់វត្តទាំងពួងឲ្យសមស័ក្តិរបស់ខ្លួន តែនឹងរកបច្ច័យសម្រាប់កសាងតាមបំណងរបស់ខ្លួនដូច្នោះពុំបាន ទើបកែប្រែបញ្ញត្តិដើមថា: បុគ្គលដែលមានទោសធ្ងន់ៗយ៉ាងណា ក៏អាចរួចទោសបានដោយការបំណាយប្រាក់កសាងវិហារនេះ (មិនបាច់នៅបរិវាសកម្ម ឬដើរធុតង្គរុក្ខមូលដូចមុនទេ) ។

រឿងនេះឯង ជាសេចក្ដីអបយសសម្រាប់សាសនា នាំឲ្យលោកអាចារ្យលូថេរធ្វេចក្នុកមិនជិតសៀមមាត់មិនកើត ទើបប្រជុំពួកអាចារ្យមកពិគ្រោះគ្នាអំពីរឿងនេះជាច្រើនលើក ហើយមូលមតិគ្នាសំរេចសេចក្ដីថាមិនត្រូវប្រតិបត្តិតាមបញ្ញត្តិរបស់សម្ដេចព្រះសង្ឃរាជឡើយ ។ ដំណឹង

នេះមិនស្ងាត់បាត់ ក៏ត្រូវទៅដល់សម្ដេចព្រះសង្ឃរាជគ្រង់រោម១ហៅលោកអាចារ្យលូថេរមកជាស់តឿនឲ្យលះបង់ទិដ្ឋិផ្ទុយទាស់នោះចោលចេញ តែអាចារ្យលូថេរមិនព្រមលះសោះ សម្ដេចព្រះសង្ឃរាជទើបធ្វើបញ្ញាជនិយកម្មបណ្ដេញលូថេរចេញ ។ តាំងអំពីកាលនោះមក លូថេរប្រកាសសេចក្ដីយល់របស់ខ្លួនដែលផ្ទុយទាស់នឹងសង្ឃរាជ ៩៥ ខ ហើយចាប់ប្រែគម្ពីរប៊ីប្លុភាសាឡាតាំងមកជាភាសាអ្នកស្រុកសាម័ញ្ញ ដើម្បីនឹងសំដែងឲ្យឃើញថាសេចក្ដីពិតសម្រាប់គ្រិស្ដសាសនានោះត្រឹមណា រួចហើយបោះពុម្ពផ្សាយសាធារណ៍ទួទៅ ។ ជនដែលមានសៀវភៅប្រែនេះកាន់ដៃ សឹងយល់ត្រូវស្របតាមលូថេរទាំងអស់ គឺយល់ឃើញថាលទ្ធិសម្ដេចព្រះសង្ឃរាជជាលទ្ធិបុរាណនោះ ក្លាំងក្លាត់ខុសចាកគម្ពីរប៊ីប្លុច្រើនណាស់ ម៉្លោះហើយលទ្ធិថ្មីនេះបេះតែផ្សាយឥទ្ធិពលកាន់តែធំទូលាយឡើង រហូតដល់ផុតអំណាចសង្ឃរាជគ្រង់រោមនឹងស្ដេចផែនដីការពារលែងបាន ។

ឯលទ្ធិថ្មីដែលលូថេរប្រកាសឡើងនោះដូច្នេះ: លូថេរប្រកាន់ទុកនូវគោលធំៗ សម្រាប់គ្រិស្ដសាសនាទាំង៣គឺ ត្រៃឯកានុភាព (Trinité)១, បាប គឺកំហុសចំពោះព្រះ (Chute)១, នឹងការលាងបាប (Rédemption)១ ហើយនឹងធម្មជាតវត្ថុ ២ យ៉ាងរបស់ព្រះគ្រិស្ដ (សាច់នឹងឈាម) ។

លូថេរបដិសេធឋានសម្រាប់ប្រព្រឹត្តតបៈញុំាងខ្លួនឲ្យបរិសុទ្ធ, ការពឹងពាក់ព្រះអរហន្ត, ការលាងបាបចំពោះបុគ្គលម្នាក់ៗ ឯង; បដិសេធពិធី

បុណ្យផ្សេងៗ ទុកតែពិធីបញ្ចូលសាសន៍ នឹងពិធីមហាស្និទ្ធ; មិនឲ្យមាន អាពមសម្រាប់ពួកនាងជី, ពួកបព្វជិតត្រូវមានប្រពន្ធបាន, ប្រកាន់ថា វត្ថុ ដែលល្អដែលសំខាន់បំផុតរបស់ព្រះយេស៊ូគ្រិស្ត នៅក្នុងនំបុ័ងនឹងស្រា ទំពាំងជូរ ។ មានសេចក្តីយល់ ២ ប្រការទៀតដែលជាគោលធំ គឺយល់ថា សេចក្ដីបរិសុទ្ធិអាស្រ័យជំនឿនឹងព្រហ្មលិខិត ។

លូថេរនឹងពួកប្រតេស្តង់យល់ថា: ជំនឿសឹងពិសេសលើសកិច្ចការ, បុគ្គលដែលជឿវត្ថុដែលគួរជឿនឹងរួចបាកទុក្ខបាន ។ ព្រហ្មលិខិត: ព្រះជាម្ចាស់សួគ៌ទ្រង់ជ្រើសរើសរកបុគ្គលតាមដែលទ្រង់ប្រាថ្នា មិនមែនសំរេចតាមចំណង់របស់មនុស្សយើងទេ ។

## សាសនាអ៊ិស្លាម

សាសនាអ៊ិស្លាម ជាលទ្ធិមួយដែលកើតឡើងក្នុងប្រទេសអារ៉ាប់ ដោយស្នាដៃថ្មីគំនិតរបស់គ្រូម្នាក់ឈ្មោះ "មោហាម៉េទ" ។ លទ្ធិនេះដែលបានឈ្មោះដូច្នេះ ដោយសំគាល់សេចក្ដីថា "ជំនឿស្រោចស្រង់សត្វ" ។

## ប្រវត្តិមោហាម៉េទ (សង្ខេប)

មោហាម៉េទ ជាសាស្ដាចារ្យរបស់ជនជាតិអារ៉ាប់, កើតនៅស្រុកមេក: (Mecque) រវាង ព. ស. ១១១៣, គ. ស. ៥៧០, ជាពូជពង្សវង្សត្រកូលរបស់ហាស្ហេម (Haschem) ដែលជាវង្សមានឈ្មោះល្បីល្បាញខ្ទរទៅក្នុងពួកកូរេស្ហ (Koréichite), កំព្រាតាំងអំពីតូច ជីតាយក

មកចិញ្ចឹម, តមកខាងក្រោយអត់អំពីជីតាទៅ បានទៅនៅអាស្រ័យនឹងឪពុកមាឈ្មោះអាប៊ូតាលេប (Abou-Talep) មានការចិញ្ចឹមជីវិតដោយពាណិជ្ជកម្ម, មានលក្ខណៈជាបុគ្គលមានសេចក្ដីក្លាហានអង់អាច, មានចិត្តសាធារណ៍ ចិត្តទូលាយ, បាននាងកដិជជៈជាស្រីមេម៉ាយមានទ្រព្យសម្បត្តិស្ដុកស្ដម្ភជាភរិយា ។ អាស្រ័យហេតុនេះ ទើបបណ្ដាលឲ្យមោហម័ទមានឥទ្ធិពល មានអានុភាពរីកធំទូលាយឡើងក្នុងជាតិរបស់ខ្លួន ។

ដល់មកអាយុ ៤០ ឆ្នាំ មោហម័ទមិនទាន់សំរេចកិច្ចការពិសេសអ្វីមួយដែលអាចឲ្យគេទាយបានថាជាមហាបុរសនៅឡើយ ។ សម័យមួយនោះគាត់ដកថយទៅរកកន្លែងស្ងប់ស្ងាត់ ដើម្បីស្ងៀមស្ងាត់ចំរើនមេត្តាភាវនា ។ រាត្រីមួយ គាត់នៅសម្ងំក្នុងរូងភ្នំហិរៈ, តាមពង្សាវតារអាក់ប៉ង់និយាយថា: មានទេពតាចុះមកហើយត្រដាងក្បួនបង្ហាញប្រាប់ថា "ឯងមើលទៅ" ។ មោហម័ទប្រកែកថា "ខ្ញុំមិនចេះអានទេ" ។ ទេពតានោះក៏ចាប់សក់លើកក្បាលទន្ទិចផ្ទប់ទៅលើផែនដីអស់៣រៈបីដង ហើយប្រាប់ម្ដងទៀតថា "អានក្បួននេះទៅ សុទ្ធតែជាព្រះនាមព្រះជាម្ចាស់ដែលបានបង្កើតវត្ថុគ្រប់យ៉ាង" ។ ម្ដងនេះ មោហម័ទអានបាន ហើយឮស្នូរសំឡេងប្រាប់មកទៀតថា "អ្នកឯងជាសាវករបស់ព្រះជាម្ចាស់ហើយ" ។

តាំងអំពីកាលនោះមក មោហម័ទបានឡើងនាមថា "នប៊ី" សំគាល់ខ្លួនថា "សព្វញ្ញូ" ចាប់ផ្ដើមប្រកាសសាសនាថ្មី ដែលខ្លួនឲ្យឈ្មោះថា

អិស្លាម "ជំនឿស្រោចស្រង់សត្វ" ។ បុគ្គលដែលមានជំនឿពិតៗ ក្នុងសាសនានេះបាននាមថា មុស៊ុលម័ន (អិស្លាមសាសនិកជន ឬ អិស្លាមិកជន) ។ ពួកនេះដំបូងមានចំនួនតិចទេ តអំពីពេលនោះរវាង ៣ ឆ្នាំ មោហាម័ទទើបតែនឹងញាំងករិយារបស់ខ្លួននឹងអាលីដែលជាបងប្អូនជីដូនមួយ ហើយនឹងខ្ញុំកំដររបស់ខ្លួន ព្រមទាំងអ្នកស្រុកមេកៈខ្លះឲ្យបូលសាសនាថ្មីបាន ។

ដល់មករវាង ព. ស. ១១៥៧, គ. ស. ៦១៤ មោហាម័ទបានប្រជុំគណៈញាតិមោក្ខបុគ្គល ដែលជាមេពួកមេត្រកូលរបស់ខ្លួនហើយសួរថា "បណ្ដាអ្នកទាំងអស់គ្នា អ្នកណាអាចធ្វើជាបងប្អូនរបស់ខ្ញុំ – ជាមេទ័ពរបស់ខ្ញុំ – ជាសេនាបតីរបស់ខ្ញុំ? ។

អាលីស្ទុះក្រោកក្រោកឡើងឆ្លើយតបថា "ខ្ញុំអាចទទួលក៏បាន បើមានទរណាមួយរើងទទឹងនឹងលោក, ខ្ញុំនឹងវាយកាប់ធ្មេញ នឹងឆ្កៀលភ្នែក នឹងវះពោះ នឹងបំបាក់ជើងចោល" ។

លទ្ធិថ្មីនេះ នាំឲ្យថ្មុយទាស់ដល់អ្នកទាំងពួងជាខ្លាំង បណ្ដាលឲ្យមានគ្រោះថ្នាក់នឹងសេចក្ដីទោមនស្សដល់ពួកកូរេស្ទជាច្រើន ។ ហេតុនោះ ទើបនាំឲ្យមោហាម័ទមានទុក្ខទោសគួរដល់សេចក្ដីស្លាប់ ក៏កៀសខ្លួនរត់ចេញពាក់ស្រុកមេកៈ ទៅនៅស្រុកអ៊ីអាគ្រែប ដែលខ្លួនឲ្យឈ្មោះថា ម៉េដីន (**Médine**) សំគាល់សេចក្ដីថា ក្រុងរបស់មោហាម័ទ ។

ការរត់ទៅនេះ ជាកិច្ចសំខាន់ក្នុងពង្សាវតារអ៊ីស្លាមិកនិកាយ ទាំងជាកាលចាប់រាប់មោហម័ទសករាជតាំងពីនោះមកផង (១៦ ស៊ូយេត៦២២) ។

មោហម័ទនៅក្នុងទីនោះ មិនយូរប៉ុន្មានក៏តាំងប្រជុំអស់មេត្រីមរបស់ខ្លួន បង្កើតជាកងទ័ពលើកចេញមកវាយពួកកូរេស្ស ត្រាតែមានជ័យជំនះ ហើយបានជាសាស្ដាចារ្យនៅស្រុកមេក:, តមកយកបានកន្លែងវិហារ "កាអាបា" ដែលជាទីបូជនីយស្ថានសម្រាប់គោរពបូជានៃពួកអារ៉ាប់ទូទៅ ហើយទាំងបានបំផ្លាញរូបសម្រាប់គោរពក្នុងទីនោះអស់ ៣០០ រូប ហើយនិយាយថា "សេចក្ដីពិតមកដល់ហើយ សេចក្ដីកុហកបូរសាបសូន្យទៅ" ។

ក្នុងរវាងពីរឆ្នាំមុនទីបំផុតអាយុរបស់មោហម័ទ ៗ បានផ្សាយសាសនាបញ្ចុះបញ្ចូលពួកអារ៉ាប់បានអស់ ៗ ក្នុង ព. ស. ១១៧៥, គ. ស. ៦៣២ មានពួកអ៊ីស្លាមិកបរិសទ្យរាប់សែននាំគ្នាទៅគោរពបូជានៅក្រុងមេក: ។ ក្នុងឆ្នាំនេះ សាស្ដាចារ្យមោហម័ទដឹងខ្លួនថាជិតដល់មរណកាលហើយ ទើបប្រកាសថា "បើខ្ញុំបានវាយបងប្អូនខ្ញុំណាមួយ ឲ្យគេវាយខ្ញុំវិញចុះ, បើខ្ញុំនៅជំពាក់បំណុលញាតិណាមួយ នេះនែប្រាក់សម្រាប់សង" ។ ខណៈនោះមានដំណាលថា: មានបុរសម្នាក់មកទារប្រាក់ចំនួន ២ — ៣ រៀល ។ មោហម័ទសងភ្លាម ដោយសេចក្ដីត្រេអរថានឹងបានរួចបំណុលក្នុងលោកនេះនឹងលោកខាងមុខ ។

# គម្ពីរកោរ៉ាន (គូអាន)

សាសនាមោហម័ទ មាននៅក្នុងផ្ទៃនៃគម្ពីរកោរ៉ានជាក្បួនសាសនា ដែលអ៊ិស្លាមិកនិកាយនិយមរាប់អានថាជាគម្ពីរដើម ដូចជាគម្ពីរប៊ីប៊្លក្នុងគ្រិស្តសាសនា ឬគម្ពីរព្រះត្រៃបិដកបែកខាងពុទ្ធសាសនារបស់យើង ។

គម្ពីរកោរ៉ាននេះមានលទ្ធិសាសនា, បញ្ញត្តិ, ផងទ ដែលមោហម័ទបានសំដែងទុកដោយកិច្ចការផ្សេង ៗ ។ គេបានចារឹកទុកដោយគោរពក្នុងស្លឹករឹត: តមកមានមោហម័ទសាវ័កម្នាក់ឈ្មោះកាលីហ្វ អាប៊ូ-បាករបានស្រង់ប្រមូលរួបរួមចារឹកចងទុកជាគម្ពីរកោរ៉ានឡើង ។

## លទ្ធិមោហម័ទ

ក្នុងគម្ពីរនេះ មានសេចក្ដីពន្យល់ថា ព្រះមានតែមួយគឺ ព្រះអាហ្វា, មោហម័ទគ្រាន់តែជាទេវទូត (របស់ព្រះអាហ្វា), ព្រលឹង (វិញ្ញាណ) មិនចេះស្លាប់, ជាតិមុខនឹងត្រូវទទួលយកផលនៃសេចក្ដីល្អនិងទោសនៃសេចក្ដីអាក្រក់ពុំខាន ។

គោលដែលសំខាន់បំផុតក្នុងសាសនានេះមាន ៣ យ៉ាងគឺ: ការសូត្រមន្ត ១ ការអត់អាហារ ១ និងការឲ្យទាន ១ ។ អ៊ិស្លាមិកជនយល់ថា ការសូត្រមន្ត ជាកិច្ចឲ្យមានដំណើរទៅរកព្រះជាម្ចាស់បានពាក់កណ្ដាលផ្លូវ, ការអត់អាហារ ឈ្មោះថាធ្វើដំណើរឲ្យបានដល់ទៅមាត់ទ្វារព៌ាំងសួគ៌, ការចែកទាន ឈ្មោះថាបាននាំងខ្លួនឲ្យចូលទៅដល់ក្នុងព៌ាំងសួគ៌ ។ (មតត)

សប្បុរិសធម្មកថា

## ព្រះទេពសត្ថា ហួរ-ហាយ ក្រុមជំនុំព្រះត្រៃបិដករៀបរៀង

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

ពេលនេះនឹងសំដែងអំពីសប្បុរស ព្រមទាំងធម៌របស់សប្បុរសដោយសេចក្ដីសង្ខេបតាមក្រសែនៃព្រះពុទ្ធដីកានិងអដ្ឋកថា ដើម្បីជាសណ្ដាប់នៃពុទ្ធបរិស័ទទាំងឡាយ ដូចសេចក្ដីដែលត្រូវសំដែងតទៅនេះ ៗ

ពាក្យថា "អ្នកសប្បុរស" គឺបុគ្គលដែលប្រកបដោយធម៌សុចរិតគ្រប់ត្រៃទ្វារគឺ កាយ វាចា ចិត្ត, ជាអ្នកឃើញប្រយោជន៍ដ៏ធំទូលាយជាសាធារណៈដល់អ្នកដទៃ, មិនឃើញត្រឹមតែប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ យ៉ាងនេះជាដើម ហៅថា "អ្នកសប្បុរសយ៉ាងឧក្រិដ្ឋ" ៗ មួយទៀតមនុស្សអ្នកមានចិត្តល្អ មានការប្រព្រឹត្តិរៀបរយត្រូវល្អចំពោះលោកអ្នកមានគុណ, ចំពោះសង្ឃគ្រហស្ថចាស់ទុំ, ជាអ្នកមានសីលធម៌គួរជាទីជ្រះថ្លាដល់ភ្នែកអ្នកផង ក៏ហៅថា "អ្នកសប្បុរស" ៗ

ពាក្យថា "សប្បុរស" នេះមកអំពីបាលីថា "**សន្តៈ**" មានអត្ថឲ្យប្រែបាន ៦ យ៉ាង គឺ:

១ — **សន្តៈ** ប្រែថា "មាន, មានគ្រប់គ្រាន់" ដូចបាលីថា

**ទ្វេ មេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា ទុល្លភា**

លោកស្មឹ "ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ មានក្នុងលោក គេរកបានដោយក្រ" ។

២ – សន្តៈ ប្រែថា "មនុស្សល្អ" ដូចបាលីថា សន្តោ ហវេ សព្ពិ បវេទយន្តិ "ពួកមនុស្សល្អ រមែងនិយាយ នឹងមនុស្សល្អ" ។

៣ – សន្តៈ ប្រែថា "ហត់នឿយ" ដូចបាលីថា ទីឃំ សន្តស្ស យោជនំ "យោជន៍វែង របស់បុគ្គលអ្នកហត់នឿយ" ។

៤ – សន្តៈ ប្រែថា "រលត់" ដូចបាលីថា អយញ្ច វិតក្កោ អយញ្ច វិចារោ សន្តា ហោន្តិ "វិតក្កនេះក្តី វិចារនេះក្តី ជាធម៌ រលត់ហើយ ។

៥ – សន្តៈ ប្រែថា "ល្អិតល្អ" ដូចបាលីថា អធិគតោ ខោ ម្យាយំ ធម្មោ សន្តោ បណីតោ "ធម៌នេះ ជាធម៌ល្អិតល្អ ប្រសើរ ដែលតថាគតត្រាស់ដឹងហើយ" ។

៦ – សន្តៈ ប្រែថា "ស្ងប់រម្ងាប់" ឬ "រៀបរយ" ដូចបាលីថា ឧបសន្តស្ស សទា សតីមតោ "បុគ្គលអ្នកស្ងប់រម្ងាប់ (ឬ រៀបរយ) មានស្មារតីគ្រប់កាលទាំងពួង" ។

ពាក្យថា "អ្នកសប្បុរស" ក្នុងទីនេះ សំដៅយកមនុស្សល្អ ឬ មនុស្សចិត្តជា ដែលមានសីលធម៌ មានសណ្តាប់ធ្នាប់ដោយកាយ វាចាចិត្ត

ជាសុចរិត អាចឲ្យអ្នកផងគួរសេពគប់ទទួលស្គាល់បាន ។ បុគ្គលរួបរួមទាក់ទងនឹងគ្នាដោយករណីយកិច្ចផ្សេងៗ តាំងពីពីរនាក់ឡើងទៅ ទោះបីជាតិជាមួយគ្នាក្ដី ជាតិផ្សេងពីគ្នាក្ដី គេហៅថា សហភាព ប្រែថា "ការនៅរួបរួមជាពួកជាមួយគ្នា" ។ ពួកជនក្នុងសហភាពនោះៗ, កាលបើគ្មានមនុស្សសប្បុរសគឺមនុស្សល្អហើយ, ទោះបីប្រកបកិច្ចការអ្វីមួយក៏មិនបានសម្រេចផលដោយល្អទេ ច្រើនតែមានឧបសគ្គស្ទាក់ដំណើរសេចក្ដីចំរើនទៅវិញ ។ មែនពិត, មនុស្សទាំងអស់ក្នុងលោក ដែលមានកិច្ចការត្រូវធ្វើ សុទ្ធតែទាក់ទងដោយពួកគណៈ បើមិនច្រើនក៏តិច, ព្រោះថាមនុស្សយើងនឹងនៅតាមទំនើងខ្លួនម្នាក់ឯង ដោយមិនបាច់ពឹងអាស្រ័យនឹងអ្នកណាមួយនោះពុំបានឡើយ ។ តាមធម្មតា មនុស្សក្នុងលោកនេះតែងមានអធ្យាស្រ័យ មានគំនិតផ្សេងៗគ្នា គឺមនុស្សខ្លះមានអធ្យាស្រ័យល្អគួរគប់រកគួររាប់អាន មានចិត្តទូលាយផ្សាយប្រយោជន៍ដល់ជាតិសាសនារបស់ខ្លួន មានសុចរិតធម៌ស្មោះត្រង់ល្អ ប្រកបដោយមេត្តាករុណាចំពោះបុគ្គលទូទៅពុំរើសមុខ មិនចំពោះតែត្រកូលគ្រួសារខ្លួនឡើយ, បុគ្គលបែបនេះ លោកហៅថា សប្បុរស ។ មនុស្សសប្បុរសកាលបើមាននៅក្នុងគណៈណា ក្នុងសមាគមណា ឬក្នុងទីប្រជុំណា រមែងបណ្ដាលឲ្យសម្រេចផលល្អ ញ៉ាំងប្រយោជន៍ឲ្យសម្រេចដោយសុវត្ថិភាព ដល់គណៈនោះ ដល់សមាគមនោះ ដល់ទីប្រជុំនោះ ដោយពិតពុំខាន ។

ព្រោះហេតុនោះ ការសេពគប់ត្រូវតែជ្រើសពិនិត្យរកបុគ្គលដែលល្អ ដោយហ្មត់ចត់ទើបជាការល្អ ។ មនុស្សខ្លះមានអធ្យាស្រ័យគ្រោតគ្រាតអាក្រក់ គ្មានសុចរិតធម៌គិតតែប្រយោជន៍ផ្ទាល់ខ្លួន មានចិត្តឫស្យាឈ្នានិសជិះជាន់លោភរកប្រយោជន៍ទាំងបំពាន គិតខាងតែបានប្រយោជន៍មកខ្លួនដោយផ្លូវទុច្ចរិត មានចិត្តប្រាសចាកមេត្តាករុណា ក្បត់ចិត្តនឹងមនុស្សជាតិផងគ្នា; បុគ្គលបែបនេះ លោកហៅថា អសប្បុរសគ្រោតគ្រាតបំផុត ។ ក្នុងប្រទេសណាឬក្នុងសមាគមណា បើមានមនុស្សអសប្បុរសនៅលាយឡំផង ប្រទេសនោះ សមាគមនោះនឹងវិនាសហិនហោចខ្សត់ខ្សោយចុះជាលំដាប់ ។

មួយទៀត ពាក្យថា "សប្បុរស" សំគាល់យកមនុស្សមានសុចរិតធម៌ ។ សុចរិតធម៌ ទុកដូចជាសញ្ញាប័ត្រមួយដ៏ប្រសើរបំផុត, កាលបើបុរសស្ត្រីណាមួយ មានសុចរិតធម៌, បុរសស្ត្រីនោះគេហៅថា មនុស្សសប្បុរស ។ សុចរិតធម៌ជាគ្រឿងសំគាល់មួយ សម្រាប់ទាយបានថាជាសប្បុរស ដែលផ្ទុយគ្នាអំពីអសប្បុរសដោយពិត ព្រោះថាធម៌របស់សប្បុរសនឹងអសប្បុរសឃ្លាងពីគ្នាដូចទិសខាងកើតនឹងទិសខាងលិច ។

ព្រះពុទ្ធសាសនា ជាសាសនាដែលសម្បូរដោយសុចរិតធម៌នេះច្រើនជាទីបំផុត, អ្នកដែលបានសន្សំសុចរិតធម៌ រមែងបាននូវសេចក្ដីសុខទាំងបច្ចុប្បន្នទាំងបរលោក ។ សុចរិតធម៌ជាមូលហេតុនៃសេចក្ដីសុខ ផ្ទុយគ្នា

នឹងទុច្ចរិត, ចំណែកឯទុច្ចរិត ក៏ជាមូលហេតុនៃសេចក្ដីទុក្ខ; ឬថា សុចរិតជាហេតុនៃសន្តិសុខ, ទុច្ចរិតជាហេតុនៃអសន្តិសុខ យ៉ាងនេះវិញក៏បាន ។ រដ្ឋាភិបាលក្នុងប្រទេសនីមួយ ៗ ក៏ត្រូវគិតអំពីសុចរិតនឹងទុច្ចរិតដែលតែងតែមាននៅក្នុងក្រសួងឲ្យណាស់ ទើបរំលាងអយុត្តិធម៌ទៅបាន ។

ពុទ្ធសាសនាឈ្មោះថា សភាសន្តិសុខផ្លូវធម៌ ដែលមានព្រះសម្មាសម្ពុទ្ធជាប្រធានរបស់សភា ។ សភាសន្តិសុខក្នុងលោក ក្រៅអំពីព្រះពុទ្ធសាសនា ឈ្មោះថា សភាសន្តិសុខផ្លូវលោក ជាសភាសម្រាប់រក្សាការពារប្រទេស ដើម្បីកុំឲ្យកើតសង្គ្រាមរវាងប្រជាជនក្នុងលោក ឬកុំឲ្យមានការចលាចលប៉ុណ្ណោះ; ទោះបីមានសភាសន្តិសុខផ្លូវលោក ព្រមទាំងមានគ្រឿងអាវុធជាជំនួយយ៉ាងនេះហើយ ក៏គង់តែកើតសង្គ្រាមឡើងបានក្នុងកាលខ្លះពុំខាន, ដូចយ៉ាងសន្និបាតជាតិនៅប្រទេសអ៊ឺរ៉ុបក្ដី អង្គការសហប្រជាជាតិនៅប្រទេសអាមេរិកក្ដី សុទ្ធតែជាសភាសន្តិសុខសម្រាប់រំលត់ភ្លើងទុក្ខក្នុងលោក បានផលខ្លះពិតមែនហើយ, តែថា សភាសន្តិសុខនេះ សម្រាប់រក្សាតែសេចក្ដីស្ងប់ខាងក្រៅតែម្យ៉ាង ។ ចំណែកខាងព្រះពុទ្ធសាសនា ជាសភាសន្តិសុខផ្លូវធម៌ដ៏ប្រសើរបំផុត ព្រោះអាចរម្ងាប់សត្វបានទាំងខាងក្នុងទាំងខាងក្រៅ ហើយនាំអ្នកសមាជិកឲ្យបានមគ្គផលនិព្វាន មានកម្មវិធីដ៏ជ្រាលជ្រៅសុខុមភាពច្រើនប្រការណាស់ ហើយគួររាប់ថាជាសភាចាស់ទុំ មានអាយុជីវិតវែងឆ្ងាយ

ណាស់មកហើយ គួរយើងជាពុទ្ធបរិស័ទរៀបចំដួសដុលឲ្យមានរបៀប ឡើង ៗ មួយទៀត សកាសន្តិសុខគឺព្រះពុទ្ធសាសនានេះមិនបាច់ប្រើ គ្រឿងអាវុធយុទ្ធភ័ណ្ឌ ដូចសកាសន្តិសុខផ្លូវលោកឡើយ ៗ ចំណែកខាងគ្រឿងអាវុធក្នុងផ្លូវព្រះពុទ្ធសាសនាក៏មានប្រើដែរ តែជាអាវុធដោយនាមធម៌ សម្រាប់គស៊ូទីងបច្ចាមិត្តគឺកិលេសមានលោភៈជាដើម មិនមែនអាវុធមានរូបដែលធ្វើអំពីវត្ថុផ្សេង ៗ មានដែកជាដើមនោះទេ ៗ

អាវុធក្នុងព្រះពុទ្ធសាសនាមាន ៣ យ៉ាង គឺ:

១ — **សុតាវុធ** ការស្តាប់, ការរៀន, ការប្រតិបត្តិធម៌ដោយគោរព, នេះឯងទុកជាអាវុធសម្រាប់ព្រះពុទ្ធសាសនា ៗ

២ — **បវិវេកាវុធ** ការនៅដោយស្ងប់ស្ងាត់ចាកពួកគណៈ, ស្ងប់ស្ងាត់ចាកកិលេសមានរាគៈជាដើម ឬស្ងប់ស្ងាត់ចាកនីវរណធម៌ទាំងឡាយមានកាមឆន្ទៈជាដើម, នេះឯងទុកជាអាវុធសម្រាប់ព្រះពុទ្ធសាសនា ៗ

៣ — **បញ្ញាវុធ** ការពិចារណាភវរកហេតុផលរបស់សេចក្តីសុខទុក្ខនិងហេតុផលនៃលក្ខណៈ ៣ យ៉ាង មានអនិច្ចលក្ខណៈជាដើមរបស់បញ្ចក្ខន្ធ; នេះឯងទុកជាអាវុធសម្រាប់ព្រះពុទ្ធសាសនា ៗ មួយទៀត ព្រះពុទ្ធសាសនាមានដំបូន្មានដ៏ល្អ ៗ ទៀតជាច្រើនណាស់ សម្រាប់

ប្រៀនប្រដៅប្រជាជនដែលមិនទាន់មានសុចរិតធម៌ ឲ្យមានសុចរិតធម៌ឡើង, ដែលមានឋានៈជាអសប្បុរសអាចធ្វើឲ្យទៅជាមនុស្សសប្បុរសឡើងបាន, ទាំងនេះឯងក៏ទុកជាអាវុធដ៏ប្រសើរដែលនាំមនុស្សឲ្យក្លាយជាសប្បុរស ។

មួយទៀត សភាគឺទីប្រជុំនិយាយការឯណាដែលមិនមានមនុស្សជាសមាជិកសប្បុរស, ទីនោះមិនឈ្មោះថាជាសភាឡើយ; សមដូចពុទ្ធភាសិតក្នុងសំយុត្តនិកាយថា:

នេសា សភា យត្ថ ន សន្តិ សន្តោ
សន្តោ ន តេ យេ ន វទន្តិ ធម្មំ
រាគញ្ច ទោសញ្ច បហាយ មោហំ
ធម្មំ វទន្តា ច ភវន្តិ សន្តោ ។

ប្រែថា "មនុស្សសប្បុរសទាំងឡាយ មិនមានក្នុងពួកណា, ពួកនោះមិនឈ្មោះថាជាសភាទេ; ពួកជនណាមិននិយាយធម៌, ពួកជននោះមិនឈ្មោះថាសប្បុរសទេ; លុះតែពួកជនដែលលះបង់នូវរាគៈ ទោសៈ មោហៈ ហើយនិយាយនូវធម៌ ទើបឈ្មោះថា "អ្នកសប្បុរស" ។

ពុទ្ធភាសិតនេះ វិនិច្ឆ័យអំពីសភារបស់សមាជិកសប្បុរសនិងអសប្បុរស ព្រមទាំងវិនិច្ឆ័យអំពីបុគ្គលដែលគួរហៅថា មនុស្សសប្បុរស ។

(ម.៦៣)

# វសលសូត្រ

### ក្នុងគម្ពីរខុទ្ទកនិកាយ សុត្តនិបាត

## ឃុនសុវត្ថិវេទី យូរ-អ៊ុន នៅពុទ្ធសាសនបណ្ឌិត្យ

### ប្រែជាពាក្យកាព្យ

ក្នុងសម័យថ្ងៃមួយព្រះអរហន្ត
ស្ដេចប្រថាប់ក្នុងវត្តជេតវ័ន ដំសោភ័ណជិតក្រុងសាវត្ថី ។
ព្រឹកមួយនោះទ្រង់ស្ដេចទៅបិណ្ឌបាត ក្នុងក្រុងស្អាតប្រោសសត្វតាម
វេណី

ជូនស្ដេចដល់ទៅផ្ទះព្រាហ្មណ៍អប្រិយ មានសញ្ញីអគ្គិការទ្វាជៈ ។
ឯព្រាហ្មណ៍នេះជាអ្នកប្រកាន់ជាតិ ពោលវិវាទដៀលត្មះដោយមានះ
ថាជាតិក្សត្រវេស្សៈឬសូទ្រៈ ពូជហីនៈមិនថ្លៃដូចជាតិព្រាហ្មណ៍ ។
ហេតុនេះហើយបានជាព្រាហ្មណ៍នោះឯង ឃើញជាក់ស្ដែងព្រះពុទ្ធ
ស្ដេចដល់ភ្លាម
មើលងាយព្រះជាតិក្សត្រមិនមែនព្រាហ្មណ៍ ពោលបេញនាមដោយ
ពាក្យមិនគប្បី ។

ថាអើស្រមណ៍កំណោរកោរត្រងោល ជាជនបោលបង្វៀតកាឡកណ្ណី
ថោកទាបពូជមិនដូចព្រាហ្មណ៍ពិសី ឈប់នៅដីកុំឡើងមកលើផ្ទះ ។
ព្រះឈ្នះមារកាលឮពាក្យបាក់ដោត ទើបត្រាស់បោទសួរទៅព្រាហ្មណ៍
មានៈ

ថាព្រាហ្មណ៍អើយស្គាល់ទេបុគ្គលខ្លះ ថោកទាបណាស់បានដល់បុគ្គល

ណា ។

មួយទៀតធម៌ដែលនាំឲ្យថោកទាប តើអ្នកជ្រាបយល់ជាក់ដោយប្រាជ្ញ

ថាបានដល់ធម៌អ្វីស្ដីមកក៉ា សព្វប្រការក្នុងកាលឥឡូវនេះ ។

ពេលនោះឯងព្រាហ្មណ៍ចាស់ពោលតបថា ខ្ញុំករុណាគ្មានដឹងគ្មានតម្រិះ

មិនអាចដោះធម៌នេះឲ្យពិសេស ហេតុដូច្នេះសូមព្រះអង្គថ្លែង ។

ព្រះសម្ពុទ្ធត្រាស់ថានែព្រាហ្មណ៍ព្រឹទ្ធ ចូរតាំងចិត្តប្រុងស្ដាប់ឲ្យខែងវែង

តថាគតនឹងទេស្នាឥឡូវឯង ដូចនឹងថែងគាថាប្រែបទកាក (គតិ) ។

១ – កោធនោ ឧបនាហី ច បាបមក្ខី ច យោ នរោ

វិបន្នទិដ្ឋិ មាយាវី តំ ជញ្ញា វសលោ ឥតិ ។

រីជនឯណា ក្រោធខឹងសម្បា គំនុំឥតស្រាន្ត ចងពៀរប្រក្រតី

អប្រិយ៍សន្តាន លុបគុណកល្យាណ ទិដ្ឋិវិបត្តិ ។ មាយាបិទបាំង

បាបអាក្រក់ខ្លាំង ប្រព្រឹត្តសម្ងាត់ រីជននោះឯង ប្រាជ្ញគួរជ្រាបថ្វាត់

ថាអ្នកថោកក្ដាត់ ទាបទន់សន្តាន(១) ។

---

• ចុងផ្ទួននៃកាព្យបទកាកគតិ ដែលប្រែពីគាថានីមួយៗ ខ្ញុំតែងឲ្យផ្ទួនជាប់គ្នានឹងពាក្យកាព្យក្នុងគាថាជាលំដាប់ៗ មក, ហេតុនេះ បើចង់កាត់រំលងបាលីគាថាចោល មើលចំពោះតែពាក្យកាព្យជាប់គ្នារហូតទៅ ក៏នឹងពីរោះដោយយ៉ាង ។

មួយទៀត ចាប់តាំងពីគាថាទី ២ រៀងទៅ ខ្ញុំតែងកាព្យកាត់ពាក្យ "ជននោះ" ចោល, ទុកចាំថាទៅដល់គាថាទី ២៖ តែម្ដង, ដែលធ្វើយ៉ាងនេះដើម្បីកុំឲ្យផ្ទួនពាក្យខ្វាត់ៗ ប៉ុណ្ណោះ ។

២- ឯកជំ វា ទ្វិជំ វាបិ យោធ បាណំ វិហឹសតិ
យស្ស បាណេ ទយា នត្ថិ តំ ជញ្ញា វសលោ ឥតិ ៗ

វីជនឯណា បៀតបៀនសត្វា ក្នុងលោកដែលមាន កំណើតតែម្តង
ឬពីរដងប្រាណ ទាំងជនដែលគ្មាន ចិត្តអាណិតសត្វ ៗ

៣- យោ ហន្តិ ឧបរុន្ធេតិ គាមានិ និគមានិ ច
និគ្គាហកោ សមញ្ញាតោ តំ ជញ្ញា វសលោ ឥតិ ៗ

ជនណាល្បីនាម សង្កត់ហុតឈាម រឹបយកសម្បត្តិ ប្លន់ស្រុកនិគម
បុរីរម្យរត្ន កៀរមនុស្សសត្វ យកជាទាសករ ៗ

៤- គាមេ វា យទិ វារញ្ញេ យំ បរេសំ មមាយិតំ
ថេយ្យា អទិន្នំ អាទេតិ តំ ជញ្ញា វសលោ ឥតិ ៗ

ជនណាលបលួច ដោយសារចិត្តលួច ទ្រព្យធនអាក្រក់ល្អ
ដែលគេកំណាន់ កម្មសិទ្ធិបរ ផ្តាច់ពីមាត់ក គេឥតមេត្តា ៗ

៥- យោ ហវេ ឥណមាទាយ ចុជ្ជមានោ បលាយតិ
ន ហិ តេ ឥណមត្ថីតិ តំ ជញ្ញា វសលោ ឥតិ ៗ

ជនណាខ្ចីបុល ទ្រព្យជាបំណុល មកបរិភោគ្គា ថ្ងៃក្រោយគេបកែ
បែរជាដោះសា ថាអ្នកអាត្មា គ្មានបំពាក់គូរ ៗ

៦- យោ វេ កិញ្ចិក្ខកម្យតា បន្ថស្មឹ វជតំ ជនំ
ហន្ត្វា កិញ្ចិក្ខមាទេតិ តំ ជញ្ញា វសលោ ឥតិ ៗ

ជនណាប្រាថ្នា បង់បានទ្រព្យ នៃអ្នកដើរផ្លូវ ហើយវាយកាប់ចាក់
ឲ្យម្ចាស់ទ្រព្យត្រូវ គ្រោះថ្នាក់ដោយនូវ គ្មានក្តីអាណិត ។

៧– យោ អត្តហេតុ បរហេតុ ធនហេតុ ច យោ នរោ
សក្ខិបុដ្ឋោ មុសា ព្រូតិ តំ ជញ្ញា វសលោ ឥតិ ។

ជនណាសាក្សី គេសួរដើម្បី ឲ្យដឹងការពិត និយាយមុសា
ព្រោះហេតុជីវិត ឯងគេដោយគិត ប្រាថ្នាទ្រព្យ ។

៨– យោ ញាតីនំ សខីនំ វា ទារេសុ បដិទិស្សតិ
សហសា សម្បិយេន វា តំ ជញ្ញា វសលោ ឥតិ ។

ជនណាកំហែង រំលោភគត់ក្រែង ទ្រុស្តក្បត់ភរិយា នៃពួកញាតិមិត្ត
ដោយគិតស្និទ្ធស្នា- គមគប់កាមការ- តម្រេកលោកិយ ។

៩– យោ មាតរំ បិតរំ វា ជិណ្ណកំ គតយោព្វនំ
បហុ សន្តោ ន ភរតិ តំ ជញ្ញា វសលោ ឥតិ ។

ជនណាមានភោគ មិនចិញ្ចឹមលោក អ្នកមានគុណក្រៃ
ដែលវ័យចាស់ជរា ទន់ទោរដើរដៃ ប្រកបការអ៊ូ លំបាកវេទនា ។

១០– យោ មាតរំ បិតរំ វា ភាតរំ ភគិនឹ សសុំ
ហន្តិ រោសេតិ វាចាយ តំ ជញ្ញា វសលោ ឥតិ ។

ជនណាធ្វើទុក្ខ ក្រោធគ្មានយល់មុខ មាតាបិតា បងប្អូនប្រុសស្រី
សស្សុសស្សុភ ដោយពោលវាចា ទ្រគោះបោកបោះ ។

១១– យោ អត្ថំ បុច្ឆិតោ សន្តោ អនត្ថមនុសាសតិ

បដិច្ឆន្នេន មន្តេតិ តំ ជញ្ញា វសលោ ឥតិ ។

ជនណាគេសួរ អំពីការគួរ មានប្រយោជន៍សោះ បែរជាក្លែងប្រាប់ ការងារមានគ្រោះ ឬប្រាប់បណ្តោះ ដោយលាក់បំបាំង ។

១២– យោ កត្វា បាបកំ កម្មំ មា មំ ជញ្ញាតិ ឥច្ឆតិ

យោ បដិច្ឆន្នកម្មន្តោ តំ ជញ្ញា វសលោ ឥតិ ។

ជនណាធ្វើបាប ហើយចង់បន្លប់ ឲ្យគេក័ន្តកាំង មិនឲ្យគេដឹង ឬប្រឹងបិទបាំង បាបអាក្រក់ខ្ទាំង មិនឲ្យស៊ុះសាយ ។

១៣– យោ វេ បរកុលំ គន្ត្វា ភុត្វា ច សុចិភោជនំ

អាគតំ នប្បដិបូជេតិ តំ ជញ្ញា វសលោ ឥតិ ។

ជនណាទៅកាន់ ផ្ទះគេ ៗ នាន់ ជូនភោជន៍សប្បាយ ដល់គេមកផ្ទះ ខ្លួនវិញខ្លួនស្តាយ មិនទទួលបាយ ដូចកាលគេសោះ ។

១៤– យោ ព្រាហ្មណំ វា សមណំ វា អញ្ញំ វាបិ វនិព្វកំ

មុសាវាទេន វញ្ចេតិ តំ ជញ្ញា វសលោ ឥតិ ។

ជនណាមុសា បញ្ឆោតព្រាហ្មណា សមណៈសូមសោះ ដោយក្លែងថា គ្មាន ឬមានតែរបស់ ថោកអន់មិនស្រស់ របស់ថ្លៃលាក់ទុក ។

១៥– យោ ព្រាហ្មណំ វា សមណំ វា ភត្តកាលេ ឧបដ្ឋិតេ

រោសេតិ វាចា ន ច ទេតិ តំ ជញ្ញា វសលោ ឥតិ ។

ពេលបាយជនណា ក្រោធដឹងសម្បា ពោលពាក្យចាក់រុក ដៀលត្មះ
ស្រមណ៍ព្រាហ្មណ៍ មិនត្រៀមកត្តុក អន្ទុយគេចមុខ ឲ្យសូមយាចក ។

១៦– អសតំ យោធ បព្រូតិ មោហេន បលិគុណ្ឋិតោ
កិញ្ចិក្ខំ និជិគីសានោ តំ ជញ្ញា វសលោ ឥតិ ។

ជនណាល្ងង់ខ្លៅ គ្មានដឹងកក់ក្ដៅ ហ៊ានទាយកុហក ប្រាប់គ្រោះកាចជា
ពេលាល្អក្រក់ ដោយចិត្តលាមក ចង់បានទ្រព្យគេ ។

១៧– យោ ចត្តានំ សមុក្កំសេ បរេ ច អវជានតិ
និហីនោ សេន មានេន តំ ជញ្ញា វសលោ ឥតិ ។

ជនណាថោកទាប ពោលលើកអត្តភាព ឲ្យខ្ពស់ល្បីកេរ្តិ៍ បង្អាប់បន្ទុះ
ពួកជននៅក្បែរ ឲ្យគ្នាខ្មាសគេ ដោយសំដីខ្លួន ។

១៨– រោសកោ កទរិយោ ច បាបិច្ឆោ មច្ឆរី សឋោ
អហិរិកោ អនោត្តប្បី តំ ជញ្ញា វសលោ ឥតិ ។

ជនណាក្រោធា ស្អប់ទានបាគា កំណាញ់មាំមួន ប្រាថ្នាលាមក
លេងកលសំនួន គ្មានខ្មាសក្នុងខ្លួន មិនមានខ្លាចបាប ។

១៩– យោ ពុទ្ធំ បរិភាសតិ . អថ វា តស្ស សាវកំ
បរិព្វាជកំ គហដ្ឋំ តំ ជញ្ញា វសលោ ឥតិ ។

ជនណាដៀលត្មះ ព្រះពុទ្ធជាម្ចាស់ សាវកសុគត ថាពុំមែនព្រះ
ថាអ្នកថោកទាប កាន់វត្តដុនដាប ពុំជាសោភ័ណ ។

២០- យោ ច អនរហំ សន្តោ   អរហំ បដិជានាតិ

ចោរោ សព្រហ្មកេ លោកេ ឯសោ ខោ វសលាធមោ

បុគ្គលណា ហ៊ានពោលប្តេជ្ញា ជាព្រះអរហន្ត លើកខ្លួនជាព្រះ
ដើម្បីបំភ័ន្ត ឲ្យពួកមហាជន គោរពកោតក្រែង ។
វិជនបណ្ឌិត ត្រូវប្រាប់តាមពិត នូវជននោះឯង ថាជាមនុស្សបាប
ចោរពាលជាក់ស្តែង អាក្រក់ក្រៃលែង ជាងសត្វពស់ខ្លា ។

ឯតេ ខោ វសលា វុត្តា មយា យេ តេ បកាសិតា

ជនពួកនោះ ៗ ដែលពោលចំពោះ ក្នុង ២០ គាថា ចាត់ជាមនុស្សថោក
គ្មានថ្លៃសោះសា លាមកមហិមា គួរចៀសវាងឆ្ងាយ ។

ន ជច្ចា វសលោ ហោតិ ន ជច្ចា ហោតិ ព្រាហ្មណោ

កម្មុនា វសលោ ហោតិ កម្មុនា ហោតិ ព្រាហ្មណោ ។

ជនដែលឈ្មោះថា ថោកទាបអន្ធការ ឬឈ្មោះថាព្រាហ្មណ៍ មិនមែន
ព្រោះជាតិ គឺព្រោះកម្មការ ដែលកើតជិតជាម ដោយទ្វារទាំងបី ។

ព្រះសម្ពុទ្ធកាលសំដែងព្រះធម៌ ដំបូវប្រោសប្រាណ ព្រាហ្មណ៍ព្រឹទ្ធា
ដល់ត្រឹមនេះទុកស្មេះបែរទ្រង់ថា ពណ៌នាជាតកមាតង្គៈ ។
ថាព្រាហ្មណ៍អើយក្នុងអតីតកាល សឹងបណ្តាលកើតរឿងរ៉ាវមកជាក់
មានបុរសឈ្មោះមាតង្គៈម្នាក់ ពូជអប្បលក្ខណ៍ចណ្ឌាលកាចឃោរឃៅ ។
បានចេញបួសជាតាបសឥសី សឹងមានល្បីកេរ្តិ៍ឈ្មោះសុះសាយទៅ

ថាជាអ្នកលុះធម៌ដ៏ជ្រាលជ្រៅ ជាសំពៅផ្ទុកសត្វកាត់សង្សា ៗ
ឥសីនេះកាន់វត្តប្រព្រឹត្តត្រូវ បានលុះនូវសមាបត្តិអភិញ្ញា
នៅអាស្រ័យក្បែរស្ទឹង ១ នាមា កុម្ភវតីនាពន្ធុមតី ៗ
ពួកក្សត្រព្រាហ្មណ៍ឮនាមតាបសនេះ ថាវិសេសដោយគុណគួរមេត្រី
បានចុះចូលថ្វាយខ្លួនសិស្សភក្តិ បំរើទ្វីតបីតិតជាតិពង្ស ៗ
ដោយបំណងគោរពចំពោះធម៌ សណ្ឋិតល្អក្នុងខ្លួនអ្នកប្រាជ្ញខ្ពង់
ប្រណិបត្តលុតក្រាបបន្ទាបអង្គ ដោយផ្ចិតផ្ចង់ទុកដាក់ហាក់ៈទេវតា ៗ
នៃព្រាហ្មណ៍អើយនៅក្បែរអាស្រមស្រស់ មានតាបសម្នាក់ទៀតជាតិព្រាហ្មណា
ធ្វើអាស្រមនៅក្រោមខ្សែជលសា ដោយប្រេជ្ញាថាខ្លួនមានជាតិខ្ពង់ ៗ
តែត្រង់គុណវិសេសក្រៅពីនេះ សឹងមិនផេះទទេគ្មានក្នុងអង្គ
ឃើញគ្រាន់មួយតែខាងបាបគ្មានបង់ ចំផិតផ្ចង់ផ្លូវទុក្ខគ្មានទំនេរ ៗ
ប្រកាន់ជាតិថាជាតិខ្លួនប្រសើរ មិនបានប្រើពស្តុអ្វីធំក្រោយគេ
ឈរដើរដេកអង្គុយអាសនេ ដំទុខ្ពេខ្ពង់ខ្ពស់ទើបសាន្តសុខ ៗ
មានថ្ងៃមួយមាតង្គៈបណ្ឌិត បានប្រព្រឹត្តប្រើប្រាស់ឈើស្ទន់មុខ
បោលបណ្តែតតាមទឹកហូរគគុក ទៅត្រោះមុខតាបសប្រកាន់ជាតិ ៗ
តាបសនោះឃើញហើយគិតខឹងថា ដើរអ្នកណាប្រមាទអញសល់ខ្នាត
បានមកនៅខាងដើមទឹកជាអាទ៍ ដោយមារយាទមើលងាយពូជពង្សអញៗ

លុះទេវទ័ងសញ្ជឹងដូច្នោះហើយ ពុំកន្តើយត្រេចតាមស្ទឹងអរញ្ញ
ដើរគន់ឈ្មោកឃើញលោកក៏ពោលផ្កាញ់ នៃវើយអញវទ័ងកាញ់ទង
ឯងណាស់ ។

ឯងឈ្មោះអ៊ូជាតិអ៊ូបូរស្តីមក កុំរះរកកកូតថាឲ្យច្បាស់
តាមឈ្មោះពិតជាតិពិតកុំក្រឡាស់ ស្តីនុភាសគេចកែបែរបិទខ្លួន ។
មាតង្គៈតាបសពោលដោះថា ខ្ញុំករុណាមាតង្គៈតាមនាមខ្លួន
ជាតិចណ្ឌាលកាចពលពីតាដូន ខ្ញុំមកតួនសាងធមិកសំពៅ ។
តាបសព្រាហ្មណ៍តបក្ដាមថានុប្ដោះ តូដថោកសោះម្ដេចហ៊ានបំពាននៅ
លើខ្សែទឹកបណ្ដែតឈើស្ទន់ទៅ ធ្វើច្រេះហៅប្រមាទជាតិព្រាហ្មណា ។
ចាប់ដើមតាំងពីត្រឹមថ្ងៃនេះទៅ ឯងកុំនៅបេញទៅកុំសង្កា
ទៅតាំងទីលំនៅក្រោមជលសា បើនៅអាអញទងដាក់សម្បថ ។
មាតង្គៈគ្មានថ្នាក់អាក់ចិន្តា ចេញយាត្រាទៅនៅតាមកំណត់
មិនយូរថ្ងៃឥសីសីលម៉ត់ចត់ ដុសមាត់មជ្ឈោលស្ទន់កងគង្គា ។
ដោយតេជៈតបៈនៃតាបស ឈើស្ទន់ស្រស់អណ្ដែតប្រាសទឹកថ្លា
មកដល់មុខតាបសជាតិព្រាហ្មណា នៅរេកទក្សិណខ្ទិនជុំអង្គ ។
ព្រាហ្មណ៍ឥសីឃើញខ្ញីនេះធុរនៅ ហាក់ដូចម្សេវត្រូវក្ដើងគ្មានការង៍
ទៅបន្ទោសហើយឲ្យតាបសខ្ជង៍ មកនៅត្រង់កន្លែងដើមដែលវិញ ។
មាតង្គៈឥសីបរិសុទ្ធច្បាប់ ស៊ូធ្វើត្រាប់បង្គាប់គ្មានទោមនេញ

ទោះទៅនៅហើយត្រូវគេបណ្តេញ  កំស៊ូចេញគ្មានចង់អាឃាត ។
តែទោះបីយ៉ាងនេះគង់តាបស  អសប្បុរសរករឿងដេរផ្តាសា
ថាឲ្យក្បាលអាងង់បែងបែកគ្នា  កង់វេលាសុរិយារះប្រាកដ ។
មាតង្គៈឮជាក់ពិគ្រោះមើល  តាបសព្រើលងងើលជាក់សម្បថ
តើត្រូវខ្លួនឬស្លួនត្រូវអ្នកស្បថ  ឃើញប្រាកដត្រូវមាត់អ្នកផ្តាសា ។
ទើបតសីទប់ខ្ចីព្រះអាទិត្យ  រុងរឿងរិទ្ធិងងឹតមិនយាត្រា
ដោយតេជានុភាពនៃអាត្មា  ព្រោះប្រាថ្នាសង្គ្រោះតាបសខិល ។
នៃព្រាហ្មណ៍អើយកាលនោះមហាជន  ដែលដើមស្ងួនស្ងៃស្ងោក្នុងករ—
វិល ដោយគ្មានថ្ងៃច្រើនថ្ងៃអាប់មន្ទិល  បាត់សុរិលប្រកបការពុំបាន ។
ទើបនាំគ្នាទៅក្រាបបង្គំសួរ  តសីតួពាលាពុតសាមាន្យ
ថាលោកម្ចាស់សូមមេត្តាប្រោសប្រាណ  ប្រាប់ដើមដានដែលថ្ងៃមិនរះ
នេះ ។
ហេតុកេទម្តេចបានជាថ្ងៃត្រែកាល  នាំបណ្តាលងងឹតជិតឈឹងម៉េះ
ឲ្យយើងខ្ញុំទុក្ខព្រួយទ្រូងស្ទើរប្រែះ  បើដូច្នេះម្តេចអេះថ្ងៃរះបាន ។
ព្រាហ្មណ៍តសីពោលខ្ចីថាអាត្មា  ខឹងសម្បានឹងតាបសមួយប្រាណ
នៅលើខ្សែទឹកក្បែរនេះដែលបាន  បណ្តាតច្រានឈើស្លូនមកលើក្តី ។
ឯអាបក្តីបានស្តីដេរផ្តាសា  ឲ្យសុរិយារះចាំងបាំងសិរសី
ឲ្យពក្សយប្រល័យចំណាំដី  តែដឹងអ៊ីថ្ងៃនេះមិនរះសោះ ។

ជនស្រីប្រុសទើបចុះទៅក្រាបអង្គ   សួរមាតង្គបណ្ឌិតគិតពិគ្រោះ
តាមដំណើរស្មើរដូចគ្នាមុននោះ   ចង់ដឹងស្មោះតាមហេតុកេទកើតមាន ៗ
មាតង្គៈបណ្ឌិតពិតតបថា   រឿងនេះអាត្មាបានរិះឃ្យាន
ឃើញទោសស្តេងលើឥសីគ្មានឈាន   ដេរបំពានអាងមានជាតិ
ព្រាហ្មណោ ៗ
ហេតុដែលថ្ងៃមិនរះព្រោះអាចក្តី   មានប្រណីជួយដោះគ្រោះថ្នាក់គេ
ទើបឃាត់ថ្ងៃមិនឲ្យរះឡើងទេ   លុះតែគេលន់តួទើបឲ្យរះ ៗ
មហាជនដឹងដើមដានដូច្នោះ   ទៅពិគ្រោះពិតទូលព្រាហ្មណ៍មានះ
ថាសូមលោកនិមន្តទៅសំពះ   លន់តួព្រះមាតង្គកង់ឥឡូវ ៗ
ព្រាហ្មណ៍ឥសីស្តីតបថាអាត្មា   ជាតិព្រាហ្មណាពូជខ្ពស់ហួសពេកកូវ
ឲ្យគំនាប់ចណ្ឌាលនោះមិនត្រូវ   តាមពិតកូវគួរគេសំពះវិញ ៗ
ជនទាំងនោះទោះចំអង្វរស្តី   ក៏ឥសីតិរមិនចរចេញ
ទើបពួកជនខឹងឃោរទោមនេញ   ស្តីបណ្តេញចាប់ចេញទាញនាំទៅ ៗ
ហើយសង្កត់ឲ្យឱនក្រាបសិរសា   ទាបបាទាមាតង្គផង់ផូរផៅ
រួចបង្គាប់ឲ្យស្មារលាទោសទៅ   តែរឹងនៅចចេសមិនចរចា ៗ
ឯមាតង្គបណ្ឌិតចិត្តសុភាព   បានដំរាបពួកជនដោយមេត្តា
ថាអត់ទោសលុះតែអ្នករាល់គ្នា   បានធ្វើការតាមបង្គាប់អាចក្តី ៗ
គឺត្រូវអ្នកយកដីមកសូនធ្វើ   ដាក់នៅលើកេសាថៃឥសី

រូបឲ្យគាត់ចុះត្រាំក្នុងវារី បន្ទឹមត្រីត្រឹមកគាត់ដោយគិត ។
បើធ្វើបោះរូបគ្រោះមិនបែកក្បាល បែកតែដីកណ្តាលសិរនោះពិត
ហើយឲ្យគាត់មុជលូនរកប្រាំងជិត ងើបឡើងសិតដោយស្និតលាងដីខ្មី ។
ពួកអ្នកស្រុកលើកគ្នានាំតាបស អសប្បុរសទៅក្នុងគង្គារី
ហើយយកភក់ពពោកជោកកេសី ទើបទូលខ្មីទៅអង្គព្រះមាតង្គ ។
ថាលោកម្ចាស់សូមឈប់សំដែងរិទ្ធិ ឲ្យងងឹតបែបនេះកុំបង្អង់
មេត្តាឲ្យអាទិត្យរះរៀងរុង ដោយស្រោចស្រង់ជីវិតយើងរាល់គ្នា ។
មាតង្គៈទ្រង់បើកព្រះសុរិយាំង រះបញ្ចាំងត្រូវត្រង់អង្គមុទ្ធា
បែកដីកក់ផូងខ្ចាយពេញគង្គា តាបសពាលាលោតមុជលូនទៅ ។
លុះងើបឡើងខ្មាសគេគេចពួនព្រៃ ដោយឃើញន័យកំហុសទោសកំលៅ
លែងចូលស្រុក ១ ជាតិរហូតទៅ អាស្រ័យនៅក្នុងព្រៃដោយក្តីទុក្ខ ។
រីពួកជនកាលឃើញហេតុអស្ចារ្យ សឹងជ្រះថ្លាក្នុងការគិច្ចទំនុក
បំរុងផ្គង់គោរពចំពោះមុខ មាតង្គទុកជាទីរាប់អានធំ ។
ឯមាតង្គលុះអង្គអស់ជន្មា ទៅកើតនាស្ថានព្រហ្មធំឧត្តម
ដោយតេជះគុណសីលដែលខិតខំ ស្មាធិ៍សន្សំធម៌អប្បមាទៈ ។
លុះព្រះពុទ្ធទេស្នចប់រឿងនេះណា ព្រាហ្មណ៍នាមថាអគ្គិភារទ្វាជៈ
ក៏ក្នុងចិត្តឥតឆ្ងល់ខ្វល់ស្ញើរស្ញុក បានយល់ថ្នាក់ថ្ងៃថោកមិនយោគជាតិ ។
ទើបក្រញូក្រាបបន្ទាបបង្គំទូល សូមខ្លួនចូលសរណាគមជាអាទិ៍

លះប្រកាន់ជាតិពូជពង្សប្រមាទ ខំសង្កាត់ស្អាងសីលនិរន្តរ ៗ

នៃបងប្អូនខេមរាសូមពិនិត្យ រឿងនេះគិតធៀបទៅនឹងផ្លូវធម៌

អ្នកគង់យល់ថាខ្មែរដែលមានក្រ អាក្រក់ល្អមិនយកជាប្រមាណ ៗ

យកសំខាន់គោលធំត្រង់អប់គុណ ធម៌ជាទុនទុកនៅក្នុងសន្តាន

ប្រុះគ្រូខ្មែរយើងទាំងអំបាលម៉ាន ខំផ្ចង់ប្រាណពប់អានធម៌បវរ ៗ

យុនសុវត្ថិវេទខ្ញុំយូរ-អ៊ុន សូមអរគុណទុកមុនដោយស្មោះសរ

ចំពោះខ្មែរបានប្រែចិត្តសញ្ចរ តាមផ្លូវធម៌, រូបខ្ញុំសុំលាហើយ ៗ

ចប់វេលសូត្រ ។

## កុំដេកចាំព្រេងសំណាង

ជោគលាភផលតែងមានដល់បុគ្គលណា
ព្យាយាមក្លាធ្វើកិច្ចការស៊ូមរណ៍អត្ត
ប្រុសក្រម៉ក់ដេកទ្រមក់ចាំព្រេងស្រង់
ចាំទល់បង់បាត់ជីវិតក៏ឥតផល ៗ
ព្រេងវាស្ថាបើវៀរការព្យាយាមម៉ាំ
មិនអាចពាំពេជ្រអំពីគិរីផ្តល់
លុះតែធ្វើនូវអំពើដោយខ្វាយខ្វល់
ជោគមកដល់ទើបបានព្រេងថែងស្មើ ៗ

យូរ.អ៊ុន

# ពិធីបុណ្យដ៏ឧឡារិក

# នៅវត្តដំណាក់ ខេត្តសៀមរាប

ព្រះមហាកែ-អឿន វត្តព្រះព្រហ្មរ័ត្ន រៀបរៀង

ឃុនសុវត្ថិវេទី យូរ–អ៊ុន ពិនិត្យកែ

---

ក្នុងពេលជិតផ្លាស់ឆ្នាំចាស់ចូលឆ្នាំថ្មី (ខាលទោស័ក ព.ស.២៤៩៣) នេះ ក្រុមពុទ្ធបរិស័ទវត្តដំណាក់ សៀមរាប មានព្រះតេជព្រះគុណព្រះសុមង្គលសិលាចារ្យ មេគណ ជាអ្នកឧបត្ថម្ភ បានផ្តើមធ្វើពិធីបុណ្យដ៏ឧឡារិកជាច្រើនផ្នែក គឺ :

១) ពុទ្ធបរិស័ទជាសិស្សានុសិស្ស មានព្រះសុមង្គលសិលាចារ្យ មេគណជាប្រធាន បាននឹករលឹកដល់គុណូបការនៃព្រះសពទាំង ៣ អង្គ គឺ : ព្រះសពនាមអ៊ិត ១ ព្រះសពនាមកុយ ១ ព្រះសពនាមឈិត ១ ជាអតីតនេវាសិក វត្តដំណាក់ ដែលសុគតទៅជាយូរឆ្នាំហើយ ។

២) បុណ្យឆ្លងសេនាសនៈ ទាំង ៨ ខ្នងជាដើម ដែលពុទ្ធបរិស័ទបានសាមគ្គីកសាងថ្វាយព្រះសង្ឃក្នុងទីវត្តដំណាក់ ។

៣) ព្រះសុមង្គលសិលាចារ្យមេគណបានប្រមូលផ្តុំសាមគ្គីចំពោះលោកគ្រូចៅអធិការ - ឧបាសក - ឧបាសិកា គ្រប់វត្តក្នុងខេត្តសៀមរាប ដើម្បីប្រមូលហិរញ្ញវត្ថុ ចូលជួយកសាងកុដិសម្រាប់ព្រះសង្ឃនាយកជាសង្ឃបិតាគណៈមហានិកាយ ក្នុងវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

៤) ដើម្បីសំបូងសម្រឹងរកសេចក្ដីសាមគ្គីចំពោះប្រទេសកម្ពុជាឲ្យបានទទួលឋានៈជាប្រទេសឯករាជ្យដោយសម្បូណ៌ ។

កាលដែលករណីយកិច្ចនេះដល់ព្រមហើយ, កុងវត្តដំណាក់ទាំងមូល, ពុកពុទ្ធបរិស័ទបានតាក់តែងដោយគ្រឿងសក្ការបូជាប្រដាប់ដោយទង់ជាតិ ស្លឹកឈើស្រស់ ប្រទីបផ្កាលាក្អៃព្រោងព្រាត ខៀវ ស ក្រហម ដំរុងរៀងទាំងកុដិ សាលា វិហារ បំពេញចិញ្ចាចពាសពេញអាកាស ដោយទើបលាបលទថ្មី គួរជាទីទស្សនាការ នៃជនានុជនដែលគមនាគមន៍ទៅមកក្នុងពេលបុណ្យនោះ ។

កម្មវិធី

ទី ១ – ថ្ងៃ ៧ មេសាឆ្នាំ ១៩៥០ វេលាយប់ម៉ោង ៨ ចំរើនព្រះបរិត្ត, តពីនោះ លោកព្រះវិជិតសេដ្ឋា អាំង-គិម-យន ថ្លែងបាឋកថា អំពីការធ្វើបុណ្យនឹងទទួលអំណរចំពោះពុទ្ធបរិស័ទ ដែលអញ្ជើញទៅជួយអនុមោទនាបុណ្យ; យប់ម៉ោង ៩ កន្លះ និមន្តព្រះអាចារ្យកែវ-អ៊ុំ សំដែងធម៌ទេសនា; ព្រឹកឡើងម៉ោង ១១ វេរកត្តដល់ព្រះសង្ឃ ចំនួន ១០០ អង្គ ។

ទី ២ – ថ្ងៃ ៨ មេសាឆ្នាំ ១៩៥០ វេលារសៀលម៉ោង ៧ មានកងឯកទេសខ្មែរទាំងប្រុសទាំងស្រីមកកាន់ធម្មស្សវនដ្ឋានជាង ១០០ នាក់ បានច្រៀងចំរៀងជាតិនិងកំរងផ្ទុនបងប្អូនស្ដាប់មើល ចំនួនមួយម៉ោង, វេលាយប់ម៉ោង ៩ លោកពលបាលឯក ចក់-ពេជ្រ ក្រុមទាហានខេមរៈភូមិន្ទ

ថ្ងៃនបាឋកថា អំពីសេចក្ដីសាមគ្គីនៃលោកគ្រូចៅអធិការគ្រប់វត្តនីងបងប្អូនរួមជាតិ ដោយក្បោះក្បាយ ចំនួនកន្លះម៉ោង; វេលាយប់ម៉ោង៩កន្លះ និមន្ត ព្រះតេជព្រះគុណព្រះមហាសុមេធាធិបតី សង្ឃនាយក ជួន-ណាត សំដែងធម្មទេសនាជាង១ម៉ោង; លុះចប់ហើយ កងឯកទេសចូលថ្វាយបង្គំ ព្រះតេជព្រះគុណសង្ឃនាយកៗ មានថេរកថាជូនពរស័ព្ទសាធុការៈចំពោះ កងឯកទេសៗ បានផ្ដើមច្រៀងចំរៀងជាតិនីងកំរងតទៅទៀត ដរាបដល់ ម៉ោង ១ យប់ ទើបឈប់ ។

ទី ៣ — ថ្ងៃ ៩ មេសា ឆ្នាំ ១៩៥០ ពិធីបុណ្យដូចថ្ងៃទី១ទី២ដែរ, ពេលនេះ មានកងឯកទេសខ្មែរទាំងប្រុសទាំងស្រីចំនួន ៥ ឡានទៅច្រើន ជាងមុន, លោកវរសេនីយត្រីនាយកកងឯកទេស នឹងលោកស្រីជាភរិយា ក៏អញ្ជើញទៅជាអធិបតី ក្នុងពិធីបុណ្យ ព្រមទាំងអស់អ្នករាជការគ្រប់ តំណែងក៏អញ្ជើញទៅជាច្រើនក្នុងពិធីបុណ្យនោះដែរ, យប់នោះព្រះតេជ ព្រះគុណសង្ឃនាយកសំដែងធម្មទេសនាទៀត; ថ្ងៃ ១០ មេសា ព្រឹក រាប់បាត្រធ្វើងបង្ហើយបុណ្យ ។

ចំនួនបរិក្ខារតែ ដែលពុទ្ធបរិស័ទមានសទ្ធាចូលក្នុងការកសាងកុដិ សម្រាប់ព្រះសង្ឃនាយក ដូចមានចំនួនតទៅនេះ គឺ:

| | | | |
|---|---|---|---|
| ស្រាក់សៀមរាប | ចំនួន | ៤៧៤១ | រៀល |
| ” ស្ទឹងត្រែង | ” | ៣៩៤០ | ” |

ស្រុកក្រឡាញ់ ចំនួន ៣.៣៥៣ រៀល

" ជីក្រែង " ៥.៥៧៥ "

" ពួក " ២.៦៩១ "

" សំរោង " ២០១ "

បូករួមទាំងអស់ចំនួន ២០.៥០១ រៀល

ក្នុងកាលបុណ្យទាំង ៣ ថ្ងៃនោះ មានពុទ្ធបរិស័ទអញ្ជើញទៅជួយអនុមោទនាជាច្រើនកុះករ ហើយសេចក្ដីជ្រះថ្លាចំពោះធម្មទេសនា និងកម្មពិធីបុណ្យជាដើម ដោយកិយោភាព ។

ក្រុមពុទ្ធបរិស័ទដែលបានផ្ដើមធ្វើកុសលនេះ មានព្រះតេជព្រះគុណព្រះសុមង្គលសីលាចារ្យមេគណជាប្រធាន សូមឧទ្ទិសកុសលរាសីនេះថ្វាយចំពោះព្រះបរមមហាក្សត្រ ព្រមទាំងសម្ដេចព្រះបរមរាជបិតាសម្ដេចព្រះវររាជជននីនាថ និងព្រះរាជវង្សានុវង្ស; ដោយតេជានុភាពនៃព្រះរតនត្រ័យនិងកុសលរាសីនេះ សូមទ្រង់ប្រកបដោយសុខសួស្ដីសិរីសុវត្ថិភាព សូមឲ្យមានព្រះជន្មាយុយឺនយូរអង្វែង ទាំងមានព្រះតេជានុភាពច្រើន; មួយទៀត សូមជូនកុសលនេះដល់រាជរដ្ឋាភិបាលរបស់ព្រះអង្គ ហើយសូមឲ្យបានសេចក្ដីសុខគ្រប់ប្រការជានិរន្តរ និងសូមឲ្យប្រទេសកម្ពុជរដ្ឋស្ថិតនៅក្នុងសន្តិភាពនិងវឌ្ឍនធម៌ អស់កាលជាយូរអង្វែងតទៅ ។

ព្រះមហា កែ - អឿន

# ចៅអធិការដែលតែងតាំងថ្មី
# របស់ក្រសួងធម្មការ
(តមក)

---

សញ្ញាប័ត្រលេខ ៦១៥ ចុះថ្ងៃចន្ទ ១៥ កើត ខែផល្គុន ឆ្នាំជូត សំរឹទ្ធិស័ក ព. ស. ២៤៩១ តាំងលោកគ្រូ សាច់-ចិក នាមធាយា ឥន្ទសត្ថា កើតឆ្នាំម្សាញ់ អាយុ ៥៦ វស្សា ៣៦ ជាគ្រូសូត្រស្តាំ វត្តនគរខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខែត្រសៀមរាប ។

សញ្ញាប័ត្រលេខ ៦១៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាប-ឡាន់ នាមធាយា ធម្មជោត កើតឆ្នាំកុរ អាយុ ៦២ វស្សា ៣៣ ជាគ្រូសូត្រឆ្វេង វត្តនគរខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខែត្រសៀមរាប ។

សញ្ញាប័ត្រលេខ ៦១៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ រាល់-សាំង នាមធាយា ឯកសុវណ្ណ កើតឆ្នាំរោង អាយុ ៤៥ វស្សា ២៥ ជាចៅអធិការ វត្តព្រៃមេលេង ឃុំព្រៃខ្លា ស្រុកកោះអណ្តែត ខែត្រតាកែវ ។

សញ្ញាប័ត្រលេខ ៦១៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុយ-ជា នាមធាយា ពុទ្ធសារោ កើតឆ្នាំមមី អាយុ ៤៣ វស្សា ២៣ ជាចៅអធិការ វត្តព្រៃកប្បាស ឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខែត្រតាកែវ ។

សញ្ញាប័ត្រលេខ ៦២០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អាត់-សយ នាមឆាយា សុធម្មប្បញ្ញោ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦២១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ករ-សួល នាមឆាយា បញ្ញាសារោ កើតឆ្នាំរកា អាយុ ២៨ វស្សា ៤ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦២២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-គុង នាមឆាយា ញាណរក្ខិត កើតឆ្នាំជូត អាយុ ៤៩ វស្សា ២៩ ជាចៅអធិការ វត្តធម្មកេរ្តិ៍ ឃុំគោកគង់ ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៦២៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សូ-ជិន នាមឆាយា ជោតត្ថេរ កើតឆ្នាំកុរ អាយុ ៥១ វស្សា ២៨ ជាចៅអធិការវត្តខ្នាយក្បាវ ឃុំត្នោតក្រឡាមាយ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦២៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ូ-ខៃ នាមឆាយា ឥន្ទសរ កើតឆ្នាំរោង អាយុ ៣៣ វស្សា ១៣ ជាចៅ-អធិការ វត្តសុវណ្ណពម ឃុំប្រែកម្ទេស ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៦២៦ ចុះថ្ងៃពុធ ១ កើតខែចេត្រ ឆ្នាំជូតសំរិទ្ធិស័ក ព.ស. ២៤៩១ តាំងលោកគ្រូ មាស-យាង នាមឆាយា ចន្ទប្បជោត កើតឆ្នាំរកា អាយុ ២៨ វស្សា ៧ ជាគ្រូសូត្រស្តាំ វត្តកំណាប់ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៦២៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទៀង-សៀម នាមឆាយា គន្ធសរ-កើតឆ្នាំ... អាយុ ៥៦ វស្សា ៧ ជាចៅអធិការវត្តពោធិវ័ន ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ ។

សញ្ញាប័ត្រលេខ ៦២៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ក់-សុម នាមឆាយា ធម្មស្សរោ កើតឆ្នាំ... អាយុ ៤៧ វស្សា ៧ ជាចៅអធិការ វត្តកំពង់ភ្នំ ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្ដាល ។

សញ្ញាប័ត្រលេខ ៦៣០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ត្រឹង-អ៊ឹម នាមឆាយា គន្ធបញ្ញា កើតឆ្នាំ គ. ស. ១៨៨៦ អាយុ ៤៨ ជាចៅអធិការ វត្តពោធិសត្ថារាម ឃុំអាំងទិញ ស្រុកឃ្លាំង កូស័ងស៊ីន ។

សញ្ញាប័ត្រលេខ ៦៣១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅ-ឃ៉ែម នាមឆាយា ឃិមមុនីជោតគោ កើតឆ្នាំខាល អាយុ ៣៥ វស្សា ១៥ វត្តកំពង់ចាម ឃុំកំពង់ចាម ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៦៣២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ា-ប្រិង នាមឆាយា មុនីមង្គលគោ កើតឆ្នាំវក អាយុ ២[illegible] វស្សា ៩ ជាគ្រូសូត្រស្ដាំ វត្តឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៣៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខឹម-ជា នាមឆាយា ជោតបញ្ញា កើតឆ្នាំវក អាយុ ២៩ វស្សា ៧ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។ (ម ៩៣)